## គម្រោងសកម្មភាពត្រួតពិនិត្យលើអ៊ីនធឺណិត

# គម្រោង iMAP ប្រទេសកម្ពុជា
# ឆ្នាំ២០២៣
# របាយការណ៍ស្ដីពីការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត

ដោយ ឡាំ សុជាតិ (API), តាន់ ថារី (API), ណុប វី (CamboJA), ឆន សុគន្ធា (CCIM), Siti Nurliza Samsudin (Sinar Project) និង Kelly Koh (Sinar Project)

បោះពុម្ព/ផលិតដោយ Sinar Project

team@sinarproject.org

https://sinarproject.org

© Sinar Project 2023

Creative Commons Attribution-ShareAlike 4.0 International License

## អំពីគម្រោង iMAP

គម្រោងសកម្មភាពត្រួតពិនិត្យលើអ៊ីនធឺណិត (iMAP) មានគោលបំណងបង្កើតបណ្តាញក្នុងតំបន់ និងក្នុងប្រទេស ដែលត្រួតពិនិត្យការជ្រៀតជ្រែកបណ្តាញ និងការរឹតបន្តឹងចំពោះសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងប្រទេសចំនួន ១០៖ មីយ៉ាន់ម៉ា កម្ពុជា ហុងកុង ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ វៀតណាម និងទីម័រខាងកើត។ គម្រោង Sinar Project បច្ចុប្បន្នកំពុងធ្វើការជាមួយដៃគូសិទ្ធិឌីជីថលជាតិនៅក្នុងប្រទេសទាំង ១០ នេះ។ គម្រោងនេះ ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធស្វែរក និងរាយការណ៍នៃកម្មវិធីតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI) ហើយវាជាប់ពាក់ព័ន្ធនឹងការថែទាំបញ្ជីគេហទំព័រ ក៏ដូចជាការប្រមូលយក និងការវិភាគការវាស់វែង។

សម្រាប់ព័ត៌មានបន្ថែម មាននៅ៖ imap.sinarproject.org
រាល់ចម្ងល់ និងការផ្តល់យោបល់អំពីរបាយការណ៍នេះ សូមទាក់ទងទៅកាន់៖ team@sinarproject.org

## របៀបប្រើប្រាស់របាយការណ៍នេះ

ការណែនាំដល់អ្នកប្រើប្រាស់៖

- ការគាំទ្រឱ្យមានភស្តុតាងលើការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត
- ការយល់ដឹងអំពីការអភិវឌ្ឍន៍ចុងក្រោយបំផុតនៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងប្រទេស ទាក់ទងនឹងវិធីសាស្ត្រនៃការបិទខ្ទប់ និងគេហទំព័រដែលរងផលប៉ះពាល់ដោយសារការត្រួតពិនិត្យពិរុទ្ធភាព។
- ការតស៊ូមតិផ្នែកគោលនយោបាយ
- ការអំពាវនាវឱ្យមានចំណាត់ការសមស្រប។

របាយការណ៍នេះមិនសំដៅធ្វើការប្រៀបធៀបការវាស់វែងនៅទូទាំងប្រទេស ឬការវាស់វែងក្នុងចំណោមប្រភេទគេហទំព័រផ្សេងៗគ្នាដែលគ្របដណ្តប់ក្រោមគម្រោង iMAP នោះទេ។

## អំពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) គឺជាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ដែលសកម្មក្នុងការតស៊ូមតិ មានឥទ្ធិពលផ្នែកគោលនយោបាយ អភិបាលកិច្ចល្អ និងការចូលរួមពីពលរដ្ឋ។ ការកសាងសមត្ថភាព និងការសម្របសម្រួលកិច្ចសន្ទនា គឺជាចំណុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងឆ្ពោះទៅរកការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាព។ ព័ត៌មានបន្ថែមមាននៅ https://apiinstitute.org/

## អំពីសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ខេមបូចា (CamboJa)

ខេមបូចា គឺជាបណ្តាញអ្នកសារព័ត៌មានអាជីពឯករាជ្យតែមួយគត់ក្នុងប្រទេសកម្ពុជា។ វាត្រូវបានបង្កើតឡើងដោយអ្នកសារព័ត៌មានមួយចំនួន រួមទាំងអតីតអ្នកយកព័ត៌មានរបស់កាសែត ខេមបូឌា ដេលី និងភ្នំពេញប៉ុស្តិ៍ ដែលអង្គភាពព័ត៌មានទាំងពីរនេះធ្លាប់ទទួលរងនូវការគាបសង្កត់ពីរដ្ឋាភិបាលក្នុងការដំណើរការនៃការបោះឆ្នោតសកលឆ្នាំ២០១៨។

ដោយសារតែការរឹតត្បិតកាន់តែខ្លាំងឡើងៗលើសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ អ្នកសារព័ត៌មានអាជីពចំនួន ២០៩ នាក់មកពីបណ្តាញសារព័ត៌មានផ្សេងៗគ្នា បានបើកកិច្ចប្រជុំមួយស្តីពីស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាកាលពីខែកុម្ភៈ ឆ្នាំ២០១៩ ក្នុងអំឡុងពេលដែលខេមបូចាត្រូវបានផ្តួចផ្តើមបង្កើតឡើង។ នៅទីបំផុត អ្នកសារព័ត៌មានចំនួន ១៥ នាក់ ក្នុងចំណោមពួកគេ បានព្រមព្រៀងបង្កើតស្ថាប័នគ្រប់គ្រងខេមបូចានេះឡើង ហើយបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល ដែលមានគោលបំណងបង្កើតជាស្ថាប័នឯករាជ្យប្រកបដោយនិរន្តរភាព អាចបំពេញបេសកកម្មលើកកម្ពស់សិទ្ធិទទួលព័ត៌មាន និងសេរីភាពសារព័ត៌មាន ពង្រឹងវិជ្ជាជីវៈអ្នកសារព័ត៌មាន និងជួយដល់ជីវភាពរស់នៅរបស់ពួកគេ។

## អំពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ត្រូវបានបង្កើតឡើងក្នុងត្រីមាសទី១ ឆ្នាំ២០០៧ ហើយបានចុះបញ្ជិកាត្រឹមត្រូវជាមួយក្រសួងមហាផ្ទៃនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៧ គឺជាអង្គការមិនមែនរដ្ឋាភិបាល (NGO)។ CCIM ត្រូវបានរៀបចំឡើងដើម្បីបម្រើការងារឆ្ពោះទៅរកការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សេរីភាពសារព័ត៌មាន សេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងសេរីភាពអ៊ីនធឺណិត។ បេសកកម្មរបស់ CCIM គឺស្រមៃចង់បានសង្គមកម្ពុជាមួយដែលពលរដ្ឋគ្រប់រូបត្រូវបានផ្តល់ព័ត៌មានដ៏ទូលំទូលាយ និងទាន់សភាពការណ៍ និងផ្តល់សិទ្ធិអំណាចក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ច និងការគោរពសិទ្ធិមនុស្ស។ CCIM បានពង្រឹងការកសាងសមត្ថភាពសម្រាប់អ្នកសារព័ត៌មានដែលស្រឡាញ់អាជីពនេះ អ្នកសារព័ត៌មានជាពលរដ្ឋ និងយុវជនទាក់ទងនឹងមូលដ្ឋានវិជ្ជាជីវៈសារព័ត៌មាន និងសិទ្ធិឌីជីថល រួមទាំងការផ្តល់ការគាំទ្រផ្នែកច្បាប់សម្រាប់អ្នកសារព័ត៌មានអាជីព និងមិនទាន់មានវិជ្ជាជីវៈ។

## អំពីគម្រោង Sinar Project

គម្រោង Sinar Project គឺជាគំនិតផ្តួចផ្តើមបច្ចេកវិទ្យាពលរដ្ឋ ដែលប្រើប្រាស់បច្ចេកវិទ្យាបើកទូលាយ ទិន្នន័យបើកទូលាយ និងការវិភាគគោលនយោបាយ ដើម្បីធ្វើឱ្យព័ត៌មានសំខាន់ៗជាប្រព័ន្ធទៅជាសាធារណៈ និងកាន់តែងាយស្រួលទទួលបានសម្រាប់ប្រជាជនម៉ាឡេស៊ី។ គម្រោងនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច និងលើកទឹកចិត្តឱ្យមានការចូលរួមពីពលរដ្ឋកាន់តែច្រើននៅក្នុងកិច្ចការសាធារណៈរបស់ប្រទេសជាតិ ដោយធ្វើឱ្យសភា និងរដ្ឋាភិបាលម៉ាឡេស៊ីកាន់តែមានការបើកទូលាយ តម្លាភាព និងគណនេយ្យភាព។ ព័ត៌មានបន្ថែមមាននៅ https://sinarproject.org។

# ពាក្យបំព្រួញ

មាតិកានៃរបាយការណ៍នេះ ត្រូវបានបញ្ជាក់ដោយពាក្យកាត់ ហើយឈ្មោះពេញត្រូវបានបញ្ជាក់នៅក្នុងតារាងខាងក្រោមនេះ។

| | |
|---|---|
| ALDR | គ្រឿងស្រវឹង និងគ្រឿងញៀន |
| ANON | ឧបករណ៍អនាមិក និងឧបករណ៍បញ្ចៀស |
| ASN | លេខប្រព័ន្ធស្វយ័តភាព |
| COMT | ឧបករណ៍ទំនាក់ទំនង |
| CTRL | ការគ្រប់គ្រងមាតិកា |
| CULTR | វប្បធម៌ |
| DRWG | ក្រុមការងារសិទ្ធិឌីជីថល |
| DNS | ប្រព័ន្ធឈ្មោះដែន |
| COMM | ពាណិជ្ជកម្មអេឡិចត្រូនិក |
| ECON | សេដ្ឋកិច្ច |
| ENV | បរិស្ថាន |
| FILE | ការចែករំលែកឯកសារ |
| GMB | ល្បែងស៊ីសង |
| GAME | ហ្គេមកំសាន្ត |
| GOVT | រដ្ឋាភិបាល |
| HACK | ឧបករណ៍លួចចូល |
| HATE | ពាក្យសម្ដីស្អប់ខ្ពើម |
| HOST | វេទិកាបង្ហោះ និងប្លក |
| HUMR | បញ្ហាសិទ្ធិមនុស្ស |
| HTTP | ពិធីសារផ្ទេរអត្ថបទទម្រង់ Hypertext |
| IGO | អង្គការអន្តររដ្ឋាភិបាល |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| iMAP | គម្រោងសកម្មភាពត្រួតពិនិត្យលើអ៊ីនធឺណិត |
| IP | ពិធីសារលើអ៊ីនធឺណិត |
| ISP | ក្រុមហ៊ុន (អ្នក) ផ្ដល់សេវាអ៊ីនធឺណិត |
| MMED | ការចែករំលែកប្រព័ន្ធផ្សព្វផ្សាយ |
| MISC | មាតិកាផ្សេងៗ |
| NEWS | សារព័ត៌មាន |
| DATE | កាលបរិច្ឆេទលើបណ្ដាញ |
| OONI | គម្រោងតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត |
| POLR | ការរិះគន់ផ្នែកនយោបាយ |

| | |
|---|---|
| PORN | ភាពអាសអាភាស |
| PROV | ការស្លៀកពាក់មិនសមរម្យ |
| PUBH | សុខភាពសាធារណៈ |
| REL | សាសនា |
| SRCH | ម៉ាស៊ីនស្វែងរក |
| XED | ការអប់រំផ្លូវភេទ |
| GRP | ទំនាក់ទំនងបណ្តាញសង្គម |
| MILX | អំពើភេរវកម្ម និងពួកសកម្មប្រយុទ្ធ |
| TCP | ពិធីសារត្រួតពិនិត្យការបញ្ជូន |
| TLS | សុវត្ថិភាពស្រទាប់ដឹកជញ្ជូន |

# តារាងមាតិកា


**អំពីគម្រោង iMAP** ........ 1

**របៀបប្រើប្រាស់របាយការណ៍នេះ** ........ 1

**អំពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)** ........ 2

**អំពីគម្រោង Sinar Project** ........ 2

**ពាក្យបំព្រួញ** ........ 3

........ 5

**តារាងមាតិកា** ........ 5

**លទ្ធផលរកឃើញសំខាន់ៗ** ........ 8

**សេចក្ដីផ្ដើម** ........ 9

**សាវតា** ........ 10

- **ទិដ្ឋភាពសង្គម នយោបាយ និងសេដ្ឋកិច្ច** ........ 10
  - សេរីភាពនៃការបញ្ចេញមតិ ........ 11
  - សេរីភាពផុតពីការជ្រៀតជ្រែក ........ 15
  - សេរីភាពផុតពីការត្រួតពិនិត្យពិរុទ្ធភាព ........ 15
  - ការចូលប្រើព័ត៌មានដោយសេរី ........ 16
  - ប្រកាសអន្តរក្រសួង (ប្រកាស) លេខ ១៧០១៧ ........ 16
  - ច្រកទ្វារអ៊ីនធឺណិតជាតិ ........ 17
  - សេចក្ដីព្រាងច្បាប់ស្ដីពីសន្តិសុខសាយប័រ ........ 18
  - អនុក្រឹត្យស្ដីពីការចុះឈ្មោះដែន ........ 18
- **ករណីដែលបានរាយការណ៍អំពីការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធ អ៊ីនធឺណិត** ........ 19
- **ទិដ្ឋភាពបណ្ដាញ** ........ 20
  - ចំនួនអាជ្ញាប័ណ្ណ ........ 22
  - ក្រុមហ៊ុនទូរសព្ទចល័ត ........ 22
  - ក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិត (ISP) ........ 20

**លទ្ធផលរកឃើញនៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធ អ៊ីនធឺណិតនៅប្រទេសកម្ពុជា** 21

- **ការបិទខ្ទប់គេហទំព័រ** ........ 22
  - គេហទំព័រដែលបានបញ្ជាក់ថាត្រូវបានបិទខ្ទប់តាមប្រភេទ ........ 25

ការបិទខ្ទប់កម្មវិធីផ្ញើសារភ្លាមៗ ........ 26
ការបិទខ្ទប់ឧបករណ៍បញ្ចៀស ........ 27
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 30
រួមចំណែកក្នុងការសិក្សា ........ 32
**សេចក្តីថ្លែងអំណរគុណ** ........ 32
**ឧបសម្ព័ន្ធ I៖ បញ្ជីគេហទំព័រដែលបានបញ្ជាក់ថាបានបិទខ្ទប់** ........ 33
**ឧបសម្ព័ន្ធ III៖ សន្ទានុក្រម** ........ 39
**ឧបសម្ព័ន្ធ IV: វិធីសាស្ត្រ** ........ 42

គេហទំព័រព័ត៌មានអនឡាញ និងគេហទំព័រផ្សេងទៀត ត្រូវបានបិទខ្ទប់ជាបណ្ដោះអាសន្ននៅក្នុងប្រទេសកម្ពុជា ជាពិសេសគេហទំព័រណាដែលផ្សព្វផ្សាយព័ត៌មានដែលត្រូវបានគេយល់ថាជាការគំរាមកំហែងដល់រដ្ឋាភិបាលកំពុងកាន់អំណាច។[1]

## លទ្ធផលរកឃើញសំខាន់ៗ

- ចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣ មានគេហទំព័រចំនួន ២,២០១ ដែលវាស់វែងដោយគម្រោងតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI Probe)។ លទ្ធផលបានបង្ហាញថានៅប្រទេសកម្ពុជាមានគេហទំព័រចំនួន ៣៧ (គេហទំព័រសកលចំនួន ២២ និងគេហទំព័រខ្មែរចំនួន ១៥) ក្នុងចំណោមគេហទំព័រសរុបចំនួន ២,២០១ ត្រូវបានបិទខ្ទប់ ឬត្រូវបានត្រួតពិនិត្យដោយរឹតត្បិតតាមរយៈមធ្យោបាយបិទខ្ទប់ប្រព័ន្ធឈ្មោះដែនពីសំណាក់ក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិត (Viettel, Ezecom, Wicam, CamSIM, ក្រុមហ៊ុនឯកជន (iSEEK)) ។វិធីសាស្ត្របិទខ្ទប់ដែលប្រើ គឺការរារាំងនៃប្រព័ន្ធ DNS ដែលគេហទំព័រនោះនឹងត្រូវបានបញ្ជូនបន្តទៅអាសយដ្ឋាន IP ដែលផុតពេលវេលាជាកម្មសិទ្ធិរបស់ ISP ឬអាសយដ្ឋាន IP bogon នៃ 127.0.0.1។ សារព័ត៌មានល្បីៗមួយចំនួន ក៏ត្រូវបានរកឃើញថាត្រូវបានត្រួតពិនិត្យដោយរឹតត្បិតផងដែរ៖ វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) វិទ្យុអាស៊ីសេរី (RFA) និងខេមបូឌា ដេលី (Cambodia Daily )។
- WhatsApp, សារហ្វេសប៊ុក (Facebook Messenger), ស៊ីញ៉ល (Signal), តេឡេក្រាម (Telegram) និងបណ្ដាញ Tor អាចចូលប្រើបាននៅទូទាំងបណ្ដាញដែលបានធ្វើតេស្តគ្រប់ទាំងអស់ក្នុងអំឡុងពេលនៃការធ្វើតេស្ត ហើយគ្មានការត្រួតពិនិត្យពិរុទ្ធភាពត្រូវបានរកឃើញសម្រាប់កម្មវិធីទាំងនោះទេ។[2]
- ផ្អែកលើការវិភាគ និងលទ្ធផលរកឃើញក្នុងរបាយការណ៍នេះ យើងសូមរំលឹកឡើងវិញនូវអនុសាសន៍ដែលធ្វើឡើងដោយ OHCHR ។ គេបានផ្ដល់អនុសាសន៍ឱ្យរដ្ឋាភិបាល (ប្រទេសកម្ពុជា) ពិនិត្យ និងកែសម្រួលឡើងវិញនូវច្បាប់បច្ចុប្បន្ន និងច្បាប់មិនទាន់សម្រេចរបស់ខ្លួន រួមទាំងអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ និងវិសោធនកម្មច្បាប់ស្ដីពីរបបសារព័ត៌មាន សេចក្ដីព្រាងច្បាប់ស្ដីពីសន្ដិសុខសាយប័រដែលបែកធ្លាយ និងសេចក្ដីព្រាងច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត។ យើងក៏សូមផ្ដល់អនុសាសន៍ផងដែរថា សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មានត្រូវបានអនុម័តដើម្បីជៀសវាងការប្រើប្រាស់បច្ចេកសព្ទមិនច្បាស់លាស់ និងការរឹតត្បិតខ្លាំងជ្រុលពេក។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានផ្ដល់អនុសាសន៍បន្ថែមដល់រដ្ឋជាភាគី ត្រូវធានាថាការបង្កើត និងការអនុវត្តច្បាប់របស់ខ្លួន រួមទាំងអនុក្រឹត្យរបស់រដ្ឋមន្ត្រី ការរឹតបន្តឹងលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការបង្កើតសមាគម ត្រូវតែអនុលោមតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃមាត្រា ១៩ (៣) និងមាត្រា ២២ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងអនុសញ្ញាស្ដីពីសិទ្ធិមនុស្ស។

[1] Freedom House. (2021). *Cambodia.* https://freedomhouse.org/country/cambodia/freedom-net/2021

[2] Even though no censorship is found here, Facebook's Response 2020 on Cambodia Human Rights Impact Assessment points “Facebook was a vital platform for human rights defenders, but defenders used it with a significant degree of self-censorship".

- រដ្ឋាភិបាលគួរតែពិនិត្យឡើងវិញ និងពិចារណាលើការលើកទឹកចិត្តចំពោះគេហទំព័រដែលបានរកឃើញថាត្រូវបានបិទខ្ទប់ដោយកម្មវិធីតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI Probe) ដែលបានអនុវត្តសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ីនធឺណិត។

## សេចក្តីផ្តើម

គេហទំព័រព័ត៌មានអនឡាញ និងគេហទំព័រផ្សេងទៀត ត្រូវបានបិទខ្ទប់ជាបណ្តោះអាសន្ននៅក្នុងប្រទេសកម្ពុជា ជាពិសេសគេហទំព័រដែលផ្សព្វផ្សាយព័ត៌មានដែលគេយល់ថាជាការគំរាមកំហែងដល់រដ្ឋាភិបាលកំពុងកាន់អំណាច។ ទោះជាយ៉ាងណាក៏ដោយ វេទិកាទាំងអស់នេះគួរតែអាចចូលប្រើបានពីគ្រប់បណ្តាញទាំងអស់ ២៤ ម៉ោងក្នុងមួយថ្ងៃ ដើម្បីលើកកម្ពស់សិទ្ធិឌីជីថល និងសេរីភាពនៃការបញ្ចេញមតិតាមរយៈវេទិកាអនឡាញ ជាពិសេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងគ្រប់គេហទំព័រទាំងអស់។

ដើម្បីពិនិត្យមើលស្ថានភាពបច្ចុប្បន្ននៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត នៅប្រទេសកម្ពុជា គម្រោងតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI) គម្រោង Sinar Project និងវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ដោយមានការចូលរួមពីក្រុមការងារសិទ្ធិឌីជីថល (DRWG) បានសហការលើការសិក្សារួមគ្នាមួយដើម្បីពិនិត្យមើលថាតើ ព្រឹត្តិការណ៍នៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត កំពុងបន្តកើតមាននៅក្នុងប្រទេស តាមរយៈការប្រមូលទិន្នន័យ និងការវិភាគការវាស់វែងបណ្តាញ ឬយ៉ាងណា។ គោលបំណងនៃការសិក្សានេះចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីបង្ហាញពីនិន្នាការនៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត។

គម្រោងតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI) គឺជាសហគមន៍សកលមួយដែលបានវាស់វែងចំពោះការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតតាំងពីឆ្នាំ២០១២មកម្ល៉េះ។ គម្រោង OONI មានគោលដៅធ្វើតេស្តលើការបិទខ្ទប់គេហទំព័រ និងកម្មវិធីអេបនានា ហើយវាស់វែងល្បឿន និងដំណើរការអនុវត្តរបស់បណ្តាញ។ ស្វែងយល់បន្ថែមអំពីគម្រោង OONI: https://ooni.org/។

ការកម្រិតនៃរបាយការណ៍នេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតដោយគម្រោង OONI ដែលទទួលបានពីប្រជាជននៅក្នុងប្រទេសកម្ពុជា និងទូទាំងពិភពលោកដែលបានដំណើរការដោយស្ម័គ្រចិត្តនូវកម្មវិធី OONI Probe ។ គោលបំណងគឺដើម្បីត្រួតពិនិត្យគេហទំព័ររបស់អង្គការ បុគ្គល ដៃគូរបស់ពួកគេ និងសមាជិកទាំងឡាយណាដែលអាចត្រូវបានបិទខ្ទប់នៅពេលណាមួយ ជាពិសេសក្នុងអំឡុងពេលបោះឆ្នោតជាតិ និងកាលៈទេសៈផ្សេងទៀត។

# សាវតា

| | |
|---|---|
| ចំនួនប្រជាជននៅខែមករា ឆ្នាំ២០២៣ | ១៦.៨៦ លាននាក់[3] |
| ការជ្រៀតចូលអ៊ីនធឺណិតនៅខែកញ្ញា ឆ្នាំ២០២២ (% នៃចំនួនប្រជាជនដែលប្រើប្រាស់អ៊ីនធឺណិត) | ១៨ លាននាក់ (១០៦.០៦%)[4] |
| ការចុះឈ្មោះប្រើទូរសព្ទចល័តក្នុងខែកញ្ញា ឆ្នាំ២០២២ (ក្នុងមនុស្ស ១០០ នាក់) | ១៩.៦០ លាននាក់ (១១៥%)[5] |
| សេរីភាពនៅលើចំណាត់ថ្នាក់ Net Ranking ក្នុងឆ្នាំ២០២២ | ៤៣/១០០; មួយផ្នែកដោយឥតគិតថ្លៃ[6] |
| សាសនា (%) | ពុទ្ធសាសនា៖ ៩៧.៩%, អ៊ីស្លាម៖ ១.១%, គ្រឹស្តសាសនា៖ ០.៥%, ផ្សេងៗ៖ ០.៦%[7] |
| ការផ្តល់សច្ចាប័ន ICCPR | រួចរាល់ |

**តារាងទី 1៖** ទិន្នន័យក្នុងបញ្ជីដែលទទួលបានពីប្រភពកសារផ្សេងៗគ្នា ហើយគ្របដណ្ដប់រយៈពេលនៃឯកសារយោងផ្សេងៗគ្នា។

# ទិដ្ឋភាពសង្គម នយោបាយ និងសេដ្ឋកិច្ច

ក្នុងអំឡុងពេលសិក្សានេះ គណបក្សភ្លើងទៀនដែលជាគណបក្សនយោបាយសេរី និងជាគណបក្សប្រឆាំងនៅប្រទេសកម្ពុជា ត្រូវបានដកហូតសិទ្ធិឈរឈ្មោះក្នុងការបោះឆ្នោតឆ្នាំ២០២៣។ គណៈកម្មាធិការរៀបចំការបោះឆ្នោត បានទាមទារឱ្យគណបក្សភ្លើងទៀនបញ្ជូនឯកសារចុះបញ្ជិកាច្បាប់ដើមពីក្រសួងមហាផ្ទៃដើម្បីចុះឈ្មោះសម្រាប់ការបោះឆ្នោត។ ឯកសារនោះត្រូវបានបាត់បង់នៅពេលដែលនគរបាលបានឆ្មក់ចូលទីស្នាក់ការកណ្ដាលរបស់គណបក្សសង្គ្រោះជាតិក្នុងឆ្នាំ២០១៧ ហើយគណបក្សនេះបានចូលរួមការបោះឆ្នោតជាបន្តបន្ទាប់ tookpart in subsequent polls ដោយបញ្ជូនឯកសារថតចម្លងរបស់ខ្លួន នេះបើយោងតាមការចេញផ្សាយរបស់សារព័ត៌មាន Aljazeera។[8]

ជាងនេះទៅទៀត នៅក្នុងការបោះឆ្នោតនីតិកាលទី៧នៅប្រទេសកម្ពុជា មានគណបក្សសរុបចំនួន ១៨ ប៉ុន្តែមិនមានគណបក្សប្រឆាំងទេ។ យុទ្ធនាការឃោសនាបោះឆ្នោតបានធ្វើឡើងពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ខណៈថ្ងៃបោះឆ្នោតត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។

# បរិយាកាសច្បាប់

[3] Digital *2023: Cambodia — DataReportal – Global Digital Insights*. (2023, February 13). DataReportal – Global Digital Insights. https://datareportal.com/reports/digital-2023-cambodia

[4] *Internet Subscriptions | Telecommunication Regulator of Cambodia. (n.d.). Internet Subscriptions | Tele*communication Regulator of Cambodia. https://trc.gov.kh/en/internet-subscriptions/

[5] *Mobile Phone Subscriptions | Telecommunication Regulator of Cambodia*. (n.d.). Mobile Phone

[6] *Cambodia: Freedom on the Net 2022 Country Report | Freedom House*. (n.d.). Freedom House. https://freedomhouse.org/country/cambodia/freedom-net/2022

[7] *Population of Cambodia 2023 | Religion in Cambodia | Find Easy*. (2021, June 6). Find Easy. https://www.findeasy.in/population-of-cambodia/

[8] *Cambodia's main opposition party barred from July election*. (202317, May 17). Cambodia's Main Opposition Party Barred From July Election | Elections News | Al Jazeera. https://www.aljazeera.com/news/2023/5/17/cambodias-main-opposition-party-barred-from-july-election

## បច្ចុប្បន្នភាពផ្នែកច្បាប់

សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ត្រូវបានដឹងឮនៅពេលដែលនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបង្ហាញសេចក្តីព្រាងចុងក្រោយ។ អង្គការសង្គមស៊ីវិល បានស្នើសុំយ៉ាងទទូចឱ្យក្រសួងចេញផ្សាយជាសាធារណៈនូវកំណែចុងក្រោយមួយនៃសេចក្តីព្រាងនេះ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ពួកគេក្នុងការផ្តល់ធាតុចូលទៅក្នុងច្បាប់មួយនេះ។ ទោះជាយ៉ាងនេះក្តី អង្គការសង្គមស៊ីវិលមិនបានទទួលការឆ្លើយតបណាមួយពីក្រសួងនោះទេ ហើយសេចក្តីព្រាងច្បាប់សន្តិសុខសាយប័រ ត្រូវបានបញ្ចូលទៅក្នុងសំណើមួយចំនួន រួចបញ្ជូនទៅនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ផ្ទុយទៅវិញ ច្បាប់ស្តីពីឯកជនភាពទិន្នន័យត្រូវបានចេញផ្សាយជាផ្លូវការដល់អង្គការសង្គមស៊ីវិលមួយចំនួន ដែលបានធ្វើការលើសម្ភារៈឌីជីថល និងសេរីភាពនៃការបញ្ចេញមតិ។ ពួកគេនឹងផ្តល់អាទិភាពដល់ការចាត់វិធានការសមស្របណាមួយដើម្បីផ្តល់ធាតុចូលទៅក្នុងច្បាប់នេះ។

ច្បាប់ស្តីពីឈ្មោះដែន (Domain Name) តម្រូវឱ្យក្រុមហ៊ុនចុះឈ្មោះដែនជាតិ (.kh) ទៅកាន់គេហទំព័រ និងអ៊ីមែលរបស់ពួកគេឱ្យបានមុនខែមករា ឆ្នាំ២០២៣។ ទោះបីជាថ្ងៃផុតកំណត់មិនបានអនុវត្តយ៉ាងតឹងតែង ក៏ដោយ[9] ក៏ច្បាប់នេះមិនបានរំលងវត្តមានចូលរួមរបស់អង្គការសង្គមស៊ីវិលនោះទេ។

ដោយសារហេតុផលការពារសុវត្ថិភាព និងសន្តិសុខជាតិ ទើបរាជរដ្ឋាភិបាលកម្ពុជាបានតាក់តែង អនុម័ត និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិច្បាប់មួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ទាំងនេះត្រូវបានរងការរិះគន់ថាវាគឺជាលិខិតុបករណ៍ដែលប្រើប្រាស់ដោយរដ្ឋាភិបាល ដើម្បីបង្កើនការត្រួតត្រារបស់ខ្លួនលើការប្រើប្រាស់អ៊ីនធឺណិត ដែលជាហេតុធ្វើឱ្យប៉ះពាល់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋក្នុងការបញ្ចេញមតិ។[10]

## សេរីភាពនៃការបញ្ចេញមតិ

### រដ្ឋធម្មនុញ្ញ

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញធានានូវសេរីភាពនៃការបញ្ចេញមតិ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តសេរីភាពនៃការបញ្ចេញមតិត្រង់មាត្រា ៤១ ចែងថា "ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ ដូចដែលបានបង្ហាញនៅក្នុងច្បាប់ជាតិក្រោយៗមកទៀត និងវិធានការមិនស្របច្បាប់ខ្លះៗ រដ្ឋអំណាចបានប្រកាសចេញយ៉ាងសកម្មនូវវិធានការណ៍ក្នុងការធានាឡើងវិញនូវសេរីភាពអ៊ីនធឺណិត ដោយផ្អែកលើហេតុផលនៃការព្រួយបារម្ភទាក់ទងនឹងកិត្តិយស សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។ មាត្រា ៤១ ក៏មានចែងអំពីបទប្បញ្ញត្តិនៃប្រព័ន្ធផ្សព្វផ្សាយត្រង់ចំណុច "របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។"

វិសោធនកម្មចុងក្រោយនៃរដ្ឋធម្មនុញ្ញឆ្នាំ២០១៨ កាន់តែកាត់បន្ថយការអនុលោមតាមស្តង់ដារអន្តរជាតិ។ វិសោធនកម្មមាត្រា ៤៩ ទាក់ទងនឹងការគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ និងការការពារជាតិ គឺជាការបង្កខូចខាតធំបំផុតចំពោះសេរីភាពជាមូលដ្ឋាន។ វិសោធនកម្មថ្មីនេះបានដាក់កាតព្វកិច្ចដូច្នេះថា "ប្រជាពលរដ្ឋខ្មែរគ្រប់រូប ប្រកាន់យកផលប្រយោជន៍ជាតិ" និងចៀសវាង "ធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដោយផ្ទាល់ ឬដោយ

---

[9] Ogden, J. (2023, January 29). *Register .kh Domain Names in Cambodia - Cambodia Begins at 40*. Cambodia Begins at 40. https://www.cambodiabeginsat40.com/?p=41005

[10] *Cambodia: Internet Censorship, Control Expanded*. (2021, February 19). Cambodia: Internet Censorship, Control Expanded | Human Rights Watch. https://www.hrw.org/news/2021/02/18/cambodia-internet-censorship-control-expanded

ប្រយោលដល់ផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ។" នៅពេលដែលបង្ហាញពីភាពចាំបាច់នៃវិសោធនកម្មនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានលើកឡើងពីក្រុមសកម្មជន ក្រុមអ្នកការពារសិទ្ធិមនុស្ស និងសមាជិកគណបក្សប្រឆាំងចំពោះការអំពាវនាវរបស់ពួកគេទៅកាន់សហគមន៍អន្តរជាតិឱ្យដាក់ទណ្ឌកម្មមកលើកម្ពុជាជុំវិញការធ្វើទុក្ខបុកម្នេញគណបក្សប្រឆាំង និងសង្គមស៊ីវិល (Nachemson & Dara, 2018)។ នៅក្នុងបរិបទនេះបង្ហាញឱ្យឃើញថា មាត្រា ៤៩ ដែលបានធ្វើវិសោធនកម្ម អាចត្រូវបានប្រើប្រាស់យ៉ាងងាយស្រួល ដើម្បីកាត់បន្ថយសេរីភាពនៃការបញ្ចេញមតិតាមអ៊ីនធឺណិត ជាពិសេសនៅពេលដែលសេចក្តីថ្លែងការណ៍បានធ្វើការរិះគន់រដ្ឋាភិបាល ឬសង្កត់ធ្ងន់លើការអំពាវនាវឱ្យចាត់វិធានការប្រឆាំងនឹងរដ្ឋាភិបាលតែម្តង។ រាល់ការជំទាស់ប្រឆាំងនឹងរដ្ឋាភិបាល អាចជំរុញឱ្យមានសកម្មភាពផ្លូវច្បាប់ដែលមិនសមាមាត្រនៃការដាក់ទណ្ឌកម្មលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ។

## ក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានបញ្ញត្តិដែលមិនច្បាស់លាស់លើពាក្យថា "ការរួមគំនិតក្បត់" ការចែករំលែក "ព័ត៌មានមិនពិត" និង "ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ដែលត្រូវបានគេប្រើដើម្បីដាក់ទោសទណ្ឌលើអ្នកប្រើប្រាស់អ៊ីនធឺណិតពីបទបង្ហោះ និងចែករំលែកមាតិការិះគន់លើបណ្តាញសង្គម។ ដោយឡែកបទបរិហារកេរ្តិ៍ត្រូវបានចែងក្រោមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ លើសពីនេះ ការផ្សព្វផ្សាយព័ត៌មានមិនពិត និងការសមគំនិតត្រូវផ្តន្ទាទោសតាមមាត្រា ៤២៥ និង ៤៥៣ រីឯច្បាប់ពាក់ព័ន្ធនឹងបទញុះញង់ និងបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋមានចែងក្នុងមាត្រា ៤៩៤ និង ៤៩៥។ វិសោធនកម្មចុងក្រោយបង្អស់ក្នុងឆ្នាំ២០១៨ បានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌនេះនូវមាត្រា ៤៣៧ ស្ទួន ឬបទប្បញ្ញត្តិអំពីការប្រមាថចំពោះអង្គព្រះមហាក្សត្រ។

មាត្រា ៣០៥ ស្តីពីបទបរិហារកេរ្តិ៍ជាសាធារណៈចែងថា "រាល់ការចោទប្រកាន់ ឬការបង្កាច់បង្ខូចដែលធ្វើឲ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គល ឬស្ថាប័ន" គឺជាបទល្មើសព្រហ្មទណ្ឌ។ បទឧក្រិដ្ឋអាចត្រូវបានប្រព្រឹត្តតាមមធ្យោបាយជាច្រើន។ ប្រភេទនៃការវាយតម្លៃទាំងនេះអនុវត្តចំពោះបទប្បញ្ញត្តិទាំងអស់ដែលបានលើកឡើងនៅក្នុងផ្នែកនេះ និងគ្របដណ្តប់សកម្មភាពទូទៅរបស់អ្នកប្រើប្រាស់អ៊ីនធឺណិតភាគច្រើន ដូចជាការសរសេរ និងការចែករំលែកនូវការបង្ហោះនៅលើវេទិកាអនឡាញ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម។ ប្រសិនបើសកម្មភាពអនឡាញទាំងនេះត្រូវបានចាត់ទុកថាជាការបរិហារកេរ្តិ៍ អំពើនេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២៤.៦០ ដុល្លារ ទៅ ២,៤៦០ ដុល្លារ។ មាត្រា ៣០៥ ស្របនឹងបទប្បញ្ញត្តិផ្សេងទៀតក្នុងក្រមព្រហ្មទណ្ឌ ត្រូវបានប្រើប្រាស់ដោយមិនសមហេតុផល ដើម្បីបំបិទមាត់ការរិះគន់របស់អ្នកនយោបាយបក្សប្រឆាំង និងអ្នករិះគន់សង្គម។

មាត្រា ៤២៥ (បទក្លែងព័ត៌មាន) បទឧក្រិដ្ឋ "ការប្រាស្រ័យទាក់ទង ឬការបើកកកាយព័ត៌មានក្លែងណាមួយដើម្បីធ្វើឱ្យជឿថានឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម ឬការធ្វើឱ្យខូចខាតប្រកបដោយគ្រោះថ្នាក់ចំពោះអ្នកដទៃ នឹងត្រូវបានអនុវត្ត" ។ ចំណុចនេះត្រូវបានអាជ្ញាធរមូលដ្ឋានប្រើប្រាស់ថាជាបទឧក្រិដ្ឋលើការផ្សព្វផ្សាយព័ត៌មានដែលពួកគេយល់ថាជាព័ត៌មានមិនពិត រួមទាំងការរិះគន់ចំៗលើរដ្ឋាភិបាលដែលពួកគេជឿថាអាចបង្កអស្ថិរភាពនយោបាយ ឬខូចខាតដល់កេរ្តិ៍ឈ្មោះរបស់ពួកគេ។ ការប្រើប្រាស់មាត្រានេះដើម្បីដាក់ទោសបុគ្គលណាម្នាក់ឱ្យប្រឈមនឹងការជាប់ពន្ធនាគារពីមួយឆ្នាំទៅពីរឆ្នាំ ឬពិន័យជាប្រាក់ចាប់ពី ៤៩០ ដុល្លារដល់ ៩៨១ ដុល្លារ។ ដូចគ្នានេះដែរ មាត្រា ៤៥៣ ស្តីពីបទសមគំនិត និងបទរួមគំនិតក្បត់ប្រឆាំងនឹងរដ្ឋាភិបាលត្រូវចាត់ទុកជាបទឧក្រិដ្ឋ "គម្រោងណាមួយដែលបង្កើតឡើងដោយមនុស្សច្រើននាក់ដើម្បីប្រព្រឹត្តបទឧបឃាត កាលបើគម្រោងនេះ ត្រូវបានសម្តែងចេញជារូបរាងច្បាស់លាស់ដោយអំពើជាក់ស្តែង

ណាមួយ ឬច្រើន ត្រូវចាត់ទុកជាអំពើរួមគំនិតក្បត់"។ បុគ្គលដែលត្រូវបានចោទប្រកាន់ អាចប្រឈមមុខនឹងការជាប់ពន្ធនាគារយ៉ាងតិចពីប្រាំឆ្នាំ និងរហូតដល់ដប់ឆ្នាំ។ មាត្រានេះត្រូវបានគេប្រើប្រាស់ដោយខុសឆ្គងដើម្បីធ្វើជាបទឧក្រិដ្ឋប្រឆាំងនឹងរដ្ឋអំណាច សូម្បីតែក្នុងករណីគ្មានភស្តុតាងបង្ហាញពីការរួមគំនិតក្បត់ក៏ដោយ។

បទប្បញ្ញត្តិដែលប្រើជាញឹកញាប់បំផុតក្នុងការធ្វើទុក្ខបុកម្នេញសមាជិកបក្សប្រឆាំង អ្នករិះគន់រដ្ឋាភិបាល ក្រុមសកម្មជន និងក្រុមអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ គឺត្រង់មាត្រា ៤៩៤ និង ៤៩៥ (ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ)។ យោងមាត្រា ៤៩៥ ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ក្នុងចំណោមមធ្យោបាយដែលមានចែងក្នុងមាត្រា ៤៩៤ ដូចនឹងមាត្រា ៣០៥ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៤ លានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ"។

មាត្រា ៤៣៧ ស្ទួន (បទប្រមាថចំពោះអង្គព្រះមហាក្សត្រ) ហាមឃាត់ចំពោះការរិះគន់អង្គព្រះមហាក្សត្រ និងកំណត់ការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ដុល្លារ ទៅ ២,៤៦០ ដុល្លារ។ បន្ទាប់ពីរបបដឹកនាំរបស់ប្រទេសថៃក្នុងការកាត់ទោសក្រុមអ្នករិះគន់នយោបាយពីបទប្រមាថព្រះមហាក្សត្រ បទប្បញ្ញត្តិនេះរំលោភបំពានលើសេរីភាពអនឡាញរបស់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម (Boyle and Chhengpor, 2018)។ អ្នកប្រើប្រាស់អ៊ីនធឺណិតអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនេះតាមរយៈ "វាចា កាយវិការ សំណេរ គំនូរ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល"។[11]

## សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឆ្នាំ ២០១៩

សេចក្តីព្រាងច្បាប់ដែលបានធ្វើបច្ចុប្បន្នភាពដែលមានការការពារចំពោះអ្នកផ្តល់ព័ត៌មាន និងមានសក្តានុពលក្នុងការជះឥទ្ធិពលជាវិជ្ជមានចំពោះការបញ្ចេញមតិដោយសេរីតាមអ៊ីនធឺណិត នឹងត្រូវអនុម័ត និងអនុវត្ត ហើយត្រូវបានចេញផ្សាយជាសាធារណៈនៅកាលពីខែសីហា ឆ្នាំ២០១៩។ សេចក្តីព្រាងច្បាប់នេះបង្កើនឱ្យមានការព្រួយបារម្ភចំពោះការប្រកាន់ខ្ជាប់នៃច្បាប់នេះទៅនឹងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាការប្រើប្រាស់ស្តង់ដារស្មោគស្មុះ និងមិនច្បាស់លាស់ដែលអាចគំរាមកំហែងដល់សិទ្ធិទទួលព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ។ ជាឧទាហរណ៍ ច្បាប់នេះបានកំណត់ដោយចង្អៀតចង្អល់អំពីប្រភេទព័ត៌មាន និងចំពោះស្ថាប័នដែលច្បាប់ត្រូវអនុវត្ត ដោយក្នុងនោះខ្វះទាំងនីតិវិធីត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព អនុញ្ញាតឱ្យអាជ្ញាធរសាធារណៈបដិសេធការលាតត្រដាងព័ត៌មាននៅក្នុងស្ថានភាពប្រថុយប្រថានពេក និងមានបទប្បញ្ញត្តិទាក់ទងនឹងបទបរិហារកេរ្តិ៍ និងបទល្មើសស្តីពីការផ្សាយបង្ខូចកេរ្តិ៍ឈ្មោះ។ នៅខែសីហា ឆ្នាំ២០២០ ច្បាប់នេះត្រូវបានពិនិត្យបញ្ចប់ ហើយត្រូវបានកំណត់ឱ្យអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី[11] ប៉ុន្តែត្រូវបានពន្យារពេលដោយសារការផ្ទុះរាលដាលនៃជំងឺរាតត្បាតកូវីដ ទើបច្បាប់នេះមិនទាន់ត្រូវបានបញ្ជូនទៅដល់សភាជាតិរហូតដល់ចុងឆ្នាំ២០២១។[11]

[11] IFJ. (2022, July 1). *Cambodia: Government needs to pass Access to Information Law.*https://www.ifj.org/media-centre/news/detail/category/press-releases/article/cambodia-governmen t-needs-to-pass-access-to-information-law.html

## ច្បាប់ស្ដីពីទូរគមនាគមន៍

ច្បាប់ស្ដីពីទូរគមនាគមន៍ឆ្នាំ២០១៥ កំណត់កាតព្វកិច្ចទូទៅលើក្រុមហ៊ុន (អ្នក) ផ្ដល់សេវាទូរគមនាគមន៍ ដែលអាជ្ញាធរអះអាងថានឹងលើកកម្ពស់លទ្ធភាពទទួលបានសេវាគ្របដណ្ដប់នៅតាមទីក្រុង និងទីជនបទ។ ទោះយ៉ាងណាក៏ដោយ បើនិយាយពីវិសាលភាពនៃបទប្បញ្ញត្តិ ច្បាប់នេះក៏មានមុខងារជាលិខិតុបករណ៍ដើម្បីតាមដានសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិតផងដែរ។ សេរីភាពនៃការបញ្ចេញមតិត្រូវរងការគំរាមកំហែងតាមរយៈការចាត់តាំងឱ្យមានមន្ត្រីអធិការកិច្ច (មាត្រា ៧០ និង ៧១) ការបន្ថយការការពារទិន្នន័យ (មាត្រា ៩៧ និង ៦) និងឧក្រិដ្ឋកម្មនៃការនិយាយដោយសេរីតាមវិទ្យុ ទូរទស្សន៍ អនឡាញ និងក្នុងសារឯកជន (មាត្រា ៨០)។

មាត្រា ៦ តម្រូវឱ្យ "គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធក្នុងវិស័យទូរគមនាគមន៍" ត្រូវផ្ដល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា"។ កង្វះនូវនិយមន័យថាតើនរណាជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការងារនេះនៅតែជាបញ្ហាដ៏ធំ ហើយអាចនាំឱ្យមានការឃ្លាំមើលតាមអំពើចិត្ត។ ដូច្នេះហើយ ប្រសិនបើច្បាប់នេះអនុញ្ញាតឱ្យមានការឃ្លាំមើលលើឧបករណ៍អេឡិចត្រូនិក នោះមានន័យថាជាការអនុញ្ញាតឱ្យអាជ្ញាធរកម្ពុជាធ្វើសកម្មភាពយ៉ាងសកម្មក្នុងការចូលស្ដាប់ការសន្ទនាតាមទូរសព្ទ និងត្រួតពិនិត្យការបញ្ចេញព័ត៌មានតាមអ៊ីនធឺណិត ដើម្បីធ្វើទុក្ខបុកម្នេញលើបុគ្គលទាំងឡាយណាដែលជាគោលដៅ។

មាត្រា ៨០ ចែងថា "ការបង្កើត ការដំឡើង និងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិស័យទូរគមនាគមន៍ កាលបើអំពើនេះនាំឱ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ"។ កង្វះនូវភាពច្បាស់លាស់លើប្រភេទនៃសកម្មភាពទូរគមនាគមន៍ អាចដាក់ទោសទណ្ឌយ៉ាងធ្ងន់ធ្ងរចំពោះការបញ្ចេញមតិស្របច្បាប់ដែលត្រូវបានផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ ទូរទស្សន៍ និងអនឡាញ និងសូម្បីតែតាមរយៈសារឯកជន និងការសន្ទនាតាមទូរសព្ទរវាងបុគ្គលនិងបុគ្គល ប្រសិនបើអាជ្ញាធរកំណត់ថាវាជាការគំរាមកំហែង។[13]

## ច្បាប់ស្ដីពីឧក្រិដ្ឋកម្មសាយប័រ (សេចក្ដីព្រាង) ឆ្នាំ២០២០

សេចក្ដីព្រាងច្បាប់នេះត្រូវបានស្នើឡើងក្នុងឆ្នាំ២០១២ ហើយអាចមានការផ្លាស់ប្ដូរបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងប្រតិកម្មរិះគន់នានា ហើយគិតត្រឹមខែសីហា ឆ្នាំ២០២១ មិនទាន់មានកាលបរិច្ឆេទជាក់លាក់ណាមួយសម្រាប់ការពិនិត្យបញ្ចប់សេចក្ដីព្រាង ឬសម្រាប់ការអនុវត្តច្បាប់នេះនៅឡើយទេ។ មាត្រា ៨ និង ១២ ចែងថាក្រុមហ៊ុន (អ្នក) ផ្ដល់សេវាត្រូវតែ "រក្សាទុកទិន្នន័យដែលចរាចរណ៍យ៉ាងហោចណាស់ ១៨០ ថ្ងៃ (ប្រហែល ៦ ខែ)" ដើម្បីចែករំលែកជាមួយ "អាជ្ញាធរមានសមត្ថកិច្ច" តាមការស្នើសុំរបស់ពួកគេ។

មាត្រា ៣២ និង ៣៣ ចាត់ទុកថាជាបទល្មើសចំពោះ "ការចូលប្រើដោយគ្មានការអនុញ្ញាត" ទៅកាន់ប្រព័ន្ធកុំព្យូទ័រ ឬការផ្ទេរទិន្នន័យពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតដោយគ្មានការអនុញ្ញាត។ ជនត្រូវចោទទាំងនោះប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ។ មាត្រាទាំងនេះក៏បង្កជាកង្វល់ដល់អ្នកផ្ដល់ព័ត៌មាន និងក្រុមអ្នកការពារសិទ្ធិមនុស្សដែលចូលប្រើព័ត៌មានទាំងនេះ ដើម្បីបង្ហាញនូវការរំលោភសិទ្ធិមនុស្សដោយរដ្ឋអំណាចដោយសារពួកគេមិនត្រូវបានផ្ដល់ការការពារគ្រប់គ្រាន់។

មាត្រា ៤០ ចាត់ទុកថាជាបទឧក្រិដ្ឋចំពោះការប្រើប្រាស់កុំព្យូទ័រដើម្បីផ្ដួចផ្ដើមឱ្យមាន "ការបង្កការរំខាន ការបង្កការភ័យខ្លាច ការគំរាមកំហែង ការបំពាន [និង] ការបំភិតបំភ័យ"។ បុគ្គលដែលរងការចោទប្រកាន់តាមមាត្រានេះ ប្រឈមនឹងការជាប់ពន្ធនាគារអតិបរមាប្រាំមួយខែ។ មាត្រា ៤៥ ចាត់ទុកថាជាបទឧក្រិដ្ឋចំពោះ "ជនណាដែលបានដឹង និងមានចេតនាធ្វើសេចក្ដីថ្លែងមិនពិត ឬការបំភាន់ជាសម្ភារៈតាមរយៈបច្ចេកវិទ្យាព័ត៌មាន" ដែលអាចធ្វើឱ្យប៉ះពាល់ដល់ "សុវត្ថិភាពសាធារណៈ" និង "សន្តិសុខជាតិ" ។

## សេរីភាពផុតពីការជ្រៀតជ្រែក

សេរីភាពសារព័ត៌មាន និងសេរីភាពអ៊ីនធឺណិតនៅប្រទេសកម្ពុជា កំពុងរងការគំរាមកំហែងកាន់តែខ្លាំងឡើងៗ។ នៅក្នុងរបាយការណ៍សេរីភាពពិភពលោកឆ្នាំ២០២២ ដែលចេញដោយអង្គការឃ្លាំមើលសេរីភាពពិភពលោក (Freedom House) បានបង្ហាញថាកម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេស" មិនសេរី"។ ប្រជាជនមានការភ័យខ្លាចក្នុងការបញ្ចេញមតិ ឬសម្តែងមតិរបស់ពួកគេតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសក្រុមអ្នកដែលរិះគន់រដ្ឋាភិបាល។ រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ច្បាប់ដែលមានស្រាប់ និងបទប្បញ្ញត្តិច្បាប់នានា ហើយបានបង្កើតច្បាប់ថ្មីៗដើម្បីបង្កើនការជ្រៀតជ្រែករបស់ខ្លួនទៀតផង។ មានការកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ក្នុងករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ហើយច្បាប់ស្តីពីជំងឺកូវីដ-១៩ ត្រូវបានប្រើប្រាស់ក្នុងករណីពាក់ព័ន្ធនឹងក្រុមអ្នកសារព័ត៌មាន និងក្រុមអ្នកការពារសិទ្ធិមនុស្សផងដែរ។

នៅឆ្នាំ២០២២ អ្នកសារព័ត៌មាននៅប្រទេសកម្ពុជាកាន់តែទទួលរងនូវការបៀតបៀន និងការគាបសង្កត់ ក៏ដូចជាអំពើហិង្សាក្នុងទម្រង់ផ្សេងៗ ចំពេលដែលមានការរឹតត្បិតកាន់តែខ្លាំងឡើងលើសេរីភាពពលរដ្ឋ និងសេរីភាពសារព័ត៌មាននៅក្នុងប្រទេស។ ជាផ្នែកមួយនៃរបាយការណ៍នេះ ក្រុមអ្នកសារព័ត៌មានចំនួន ៦៥ នាក់ត្រូវបានសម្ភាស និងស្ទង់មតិ។ អ្នកឆ្លើយតបទាំងអស់ចំពោះការស្ទង់មតិនេះបាននិយាយថា ពួកគេបានប្រឈមមុខនឹងទម្រង់នៃការជ្រៀតជ្រែកក្នុងដំណើរការបំពេញការងាររបស់ពួកគេ ខណៈដែលជាង ៨០% នៃអ្នកដែលបានស្ទង់មតិបាននិយាយថា ពួកគេធ្លាប់ត្រូវបានគេឃ្លាំមើល និងត្រូវបានរឹតបន្តឹងដោយមិនស្មើភាព ឬដោយមិនចាំបាច់ រួមទាំងពាក់ព័ន្ធនឹងការទទួលព័ត៌មានផងដែរ។[14]

## សេរីភាពផុតពីការត្រួតពិនិត្យពិរុទ្ធភាព

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការត្រួតពិនិត្យពិរុទ្ធភាពក្នុងទម្រង់ផ្សេងៗគ្នាបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ ការដាក់កំហិតដោយវិធានការផ្លូវច្បាប់ និងមិនស្របច្បាប់ដោយរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងក្រុម ឬបុគ្គលជាគោលដៅ បានរឹតបន្តឹងជាអវិជ្ជមានចំពោះសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ីនធឺណិត។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានអះអាងថា ទោះបីជាប្រកាសលេខ ១៧០ ឬអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានកំណត់គោលដៅជាពិសេសទៅលើប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ក៏ផលប៉ះពាល់ដែលអាចកើតមានពីលិខិតុបករណ៍ទាំងនេះលើសេរីភាពនៃការបញ្ចេញមតិកាន់តែទូលំទូលាយ ហើយសេរីភាពសារព័ត៌មានកាន់តែស៊ីជម្រៅ។ លិខិតុបករណ៍ទាំងពីរនេះផ្តល់អំណាចយ៉ាងទូលំទូលាយសម្រាប់រដ្ឋាភិបាលក្នុងការត្រួតពិនិត្យពិរុទ្ធភាពលើការបញ្ចេញមតិក្នុងលក្ខណៈដែលមើលទៅដំណើរការល្អហួសពីអ្វីដែលត្រូវបានអនុញ្ញាតដោយមាត្រា ១៩ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ជាហេតុបណ្តាលឱ្យកើតមាននូវស្ថានភាពដែលភ្នាក់ងាររដ្ឋាភិបាលនឹងត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការត្រួតពិនិត្យពិរុទ្ធភាពលើការបញ្ចេញមតិ និងរាយការណ៍ថាមានភាពរអាក់រអួល។ ក្នុងអំឡុងការបោះឆ្នោតជាតិកាលពីឆ្នាំ ២០១៨ កន្លងទៅ ក្រសួងព័ត៌មានបានបញ្ជាឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISPs) បិទសេវារបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឬគេហទំព័រព័ត៌មានសរុបចំនួន ១៥។

ដូច្នេះហើយទើបមានការលើកឡើងថា ប្រកាសលេខ ១៧០ និងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិគំរាមកំហែងដល់មូលដ្ឋានច្បាប់ជាផ្លូវការបន្ថែមទៀតចំពោះការបិទគេហទំព័រ។ នេះរាប់បញ្ចូលទាំងគេហទំព័ររបស់បណ្តាញព័ត៌មានដែលបណ្តាលឱ្យមានការភ័យខ្លាចចំពោះការញុះញង់ និងបិទសំឡេងរិះគន់ និងការរាយការណ៍ព័ត៌មាន។

ជាទូទៅ ប្រជាជនកម្ពុជាខ្លាចមិនហ៊ាននិយាយប្រឆាំងនឹងរបបកាន់អំណាចនោះទេ។ យោងតាមការសិក្សាថ្មីមួយដែលធ្វើឡើងដោយ Asiacenter បានឱ្យដឹងថាបុគ្គលម្នាក់ៗបានត្រឹមតែចូលចិត្តអាន ឬស្ដាប់មាតិកានយោបាយ ជាជាងការចែករំលែកទស្សនៈនយោបាយផ្ទាល់ខ្លួនរបស់ពួកគេតាមអ៊ីនធឺណិត ឬជាជាងការចូលរួមក្នុងព្រឹត្តិការណ៍នយោបាយ ដោយសារពួកគេខ្លាចមានបញ្ហាជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលបានបង្កើនអំណាចគ្រប់គ្រងរបស់ខ្លួនលើបណ្ដាញអ៊ីនធឺណិត។

ថ្មីៗនេះក្នុងឆ្នាំ២០២២ របាយការណ៍របស់ OHCHR ដែលបានសម្ភាសក្រុមអ្នកកាសែតបុរសចំនួន ១៥ នាក់ និងស្ត្រី ៦ នាក់ បានបង្ហាញថា ៦០% នៃពួកគេធ្លាប់បានប្រឈមមុខនឹងការគំរាមកំហែងដោយពាក្យសម្ដីទាក់ទងនឹងការងាររបស់ពួកគេ។ ការសិក្សាមួយផ្សេងទៀតបានកត់សម្គាល់ថា ហ្វេសប៊ុក (Facebook) គឺជាវេទិកាអនឡាញដែលត្រូវបានគេឃ្លាំមើលច្រើនជាងគេបំផុត ក្នុងនោះការរឹតបន្តឹងលើសេរីភាពនៃការបញ្ចេញមតិមានចំនួន ៤៦ ករណី បន្ទាប់មកគឺ TikTok (៨ ករណី) និង YouTube (៧ ករណី)។[15]

## ការចូលប្រើព័ត៌មានដោយសេរី

ស្របតាមស្តង់ដារ និងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងការទទួលបានព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិមួយចំនួនរបស់ប្រទេសកម្ពុជា បានធានាចំពោះការទទួលបានព័ត៌មាន (មាត្រា ២១)។ បទប្បញ្ញត្តិចំនួនបីនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន ផ្តល់នូវការគូសបញ្ជាក់ដោយស្របច្បាប់ស្ដីពីសិទ្ធិដែលត្រូវបានការពារចំពោះ "ការទទួលបានព័ត៌មានប្រកបដោយគុណភាពខ្ពស់ និងត្រឹមត្រូវដែលកាន់កាប់ដោយរដ្ឋាភិបាលកម្ពុជា និងស្ថាប័នសាធារណៈផ្សេងទៀត" ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

មាត្រា ៥ នៃច្បាប់ព័ត៌មានទទួលស្គាល់ "សិទ្ធិទទួលបានព័ត៌មាននៅក្នុងកំណត់ត្រាដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ មាត្រា ១៣ នៃច្បាប់បណ្ណសារឆ្នាំ២០០៥ ចែងថាៈ បណ្ណសារសាធារណៈដែលជាឯកសារបោះពុម្ពផ្សាយ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ដោយសាធារណជនសម្រាប់ការស្រាវជ្រាវ និងពិគ្រោះយោបល់ជាព័ត៌មានដែលមិនមានការរឹតបន្តឹង។ សកម្មភាពសាធារណៈផ្សេងទៀតត្រូវបានអនុញ្ញាតសម្រាប់ការស្រាវជ្រាវដោយសេរីរយៈពេល ២០ ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃឯកសារ ឬបន្ទាប់ពីចុងបញ្ចប់នៃដំណើរការ ឬក្នុងករណីពិសេសដែលមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ។[16] ច្បាប់ព័ត៌មាននៅតែមាននៅក្នុងសេចក្តីព្រាងកំណែរហូតដល់ចុងឆ្នាំ២០២១ ចាប់តាំងពីកំណែដំបូងត្រូវបានព្រាងកាលពីឆ្នាំ២០០៧។

ទោះជាយ៉ាងណាក៏ដោយ ការចូលប្រើប្រាស់ព័ត៌មានដោយសេរីនៅតែជាបញ្ហាប្រឈមដ៏ធំមួយ។ ការសិក្សាថ្មីមួយរបស់ OHCHR លើអ្នកសារព័ត៌មាន បានលើកឡើងថា អ្នកសារព័ត៌មានកំពុងធ្វើការក្នុងបរិយាកាសលំបាកកាន់តែខ្លាំងឡើង ជាពិសេសគឺពិបាកក្នុងការទទួលព័ត៌មានពីប្រភពសាធារណៈ។ ខណៈពេលដែលអាជ្ញាធរបានអនុម័តច្បាប់នានាដែលហាក់ដូចជាសំដៅរារាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ពួកគេក៏បានពន្យារពេលពិនិត្យបញ្ចប់ច្បាប់ថ្មីដែលបានសន្យាថានឹងអនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយអាចទទួលបានព័ត៌មានផ្លូវការ។

## ប្រកាសអន្តរក្រសួង (ប្រកាស) លេខ ១៧០១៧

ប្រកាសនេះ ត្រូវបានអនុវត្តចំពេលបរិយាកាសនៃការគ្រប់គ្រងដ៏តឹងតែងនៅលើវេទិកាអនឡាញក្នុងអំឡុងពេលបោះឆ្នោតជាតិ ដូចជាការបិទខ្ទប់គេហទំព័រដែលមានទំនោរគាំទ្រលទ្ធិប្រជាធិបតេយ្យ ជាដើម។ ការចេញដំបូងរបស់ប្រកាសនេះអនុញ្ញាតឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីត្រួតពិនិត្យការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។ បទប្បញ្ញត្តិ

នេះកំណត់គោលដៅផ្ទាល់លើការបោះពុម្ពផ្សាយគេហទំព័រ និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងលំហអ៊ីនធឺណិតកម្ពុជា។ យោងតាមប្រការ៦ ក្រសួងព័ត៌មានត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងព័ត៌មានអនឡាញទាំងឡាយដែលបានបោះពុម្ពផ្សាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក និង "ចាត់វិធានការ" ប្រឆាំងនឹងការបោះពុម្ពផ្សាយទាំងឡាយណាដែលខុសច្បាប់។

ខណៈពេលដែលប្រកាសអន្តរក្រសួងជារឿយៗត្រូវបានគេហៅថាជាច្បាប់ស្តីពី "ព័ត៌មានក្លែងក្លាយ" របស់ប្រទេសកម្ពុជា វាកម្រនឹងត្រូវបានគេប្រើដើម្បីដាក់ទោសទណ្ឌចំពោះអំពើនៃការផ្សព្វផ្សាយព័ត៌មានមិនពិត។ ផ្ទុយទៅវិញ វាច្រើនតែត្រូវបានប្រើប្រាស់សម្រាប់ជាយុត្តិកម្មសម្រាប់ការឃ្លាំមើលឌីជីថលរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។

## ច្រកទ្វារអ៊ីនធឺណិតជាតិ

អនុក្រឹត្យនេះ សំដៅបង្កើនសមត្ថភាពត្រួតពិនិត្យយ៉ាងហ្មត់ចត់លើសកម្មភាពរបស់អ្នកប្រើប្រាស់ ដោយហេតុថាប្រតិបត្តិករច្រកទ្វារនឹងត្រូវរាយការណ៍ពីការសង្កេតរបស់ពួកគេលើការប្រើប្រាស់អ៊ីនធឺណិត ទៅកាន់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ស្រដៀងទៅនឹងប្រកាសអន្តរក្រសួងដែរ ច្បាប់នេះសំដៅដល់ការឃ្លាំមើលតាមអ៊ីនធឺណិតរបស់រដ្ឋាភិបាល ជាជាងការប្រព្រឹត្តិបទឧក្រិដ្ឋតាមអ៊ីនធឺណិត។ ដូច្នេះហើយ គោលការណ៍ថ្មីនេះ គឺជាលិខិតុបករណ៍ដ៏មានសក្តានុពលខ្ពស់ប្រឆាំងនឹងការបញ្ចេញមតិតាមអ៊ីនធឺណិត និងសិទ្ធិឯកជនភាព។

មាត្រា ៦ នៃឯកសារច្បាប់មានពិពណ៌នាអំពីមុខងារ និងភារកិច្ចរបស់ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ដែលរួមបញ្ចូលទាំងការងារគ្រប់គ្រងការចូលប្រើសេវាតភ្ជាប់បណ្តាញ និងសេវាអ៊ីនធឺណិត។ ដោយសារតែបទប្បញ្ញត្តិមិនច្បាស់លាស់ និងស្មុគស្មាញ មាត្រានេះអនុញ្ញាតឱ្យរដ្ឋាភិបាលរារាំងការចូលទៅកាន់គេហទំព័រដែលហ៊ានផ្សព្វផ្សាយទស្សនៈរិះគន់រដ្ឋាភិបាល ដោយដាក់ស្លាកសញ្ញាថាជាព័ត៌មានបែបគំរាមកំហែងដល់សណ្តាប់ធ្នាប់ ឬសុវត្ថិភាពសង្គមទៅវិញ។

មាត្រា ១២ (កិច្ចការកៀរគរចំណូល ការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ) ក៏តម្រូវឱ្យប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវតែ "[ធានា] ការពារសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គម ក៏ដូចជាការបិទខ្ទប់ និងបង្ក្រាបអំពើល្មើស"។ និយមន័យមិនច្បាស់លាស់ និងការវាយតម្លៃក៏មិនច្បាស់លាស់ចំពោះអ្វីដែលអាចចាត់ថាជាបទឧក្រិដ្ឋ ឬសកម្មភាពណាដែលគំរាមកំហែងដល់ "សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់" ដែលអាចអនុញ្ញាតឱ្យបន្តការចាប់ពិរុទ្ធដោយហេតុផលនយោបាយចំពោះសកម្មជនអនឡាញ និងអ្នកប្រើប្រាស់អ៊ីនធឺណិត។ អ្នកផ្តល់សេវា ក៏ត្រូវតែជំរុញឱ្យអ្នកប្រើប្រាស់បំពេញទម្រង់អនឡាញ និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេផងដែរ៖ ការប្រមូលទិន្នន័យបែបនេះ ដោយគ្មានការការពារសុវត្ថិភាពដែលមានស្រាប់លើភាពឯកជននៃទិន្នន័យ អាចបណ្តាលឱ្យមានការប្រើប្រាស់ទិន្នន័យនេះដើម្បីឃ្លាំមើល និងតាមដានសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិត។ ដោយសារការត្រួតពិនិត្យពិរុទ្ធភាពបែបនេះគឺជារឿងធម្មតាទៅហើយនៅក្នុងប្រទេសកម្ពុជា ទើបច្រកទ្វារអ៊ីនធឺណិតជាតិ បានត្រឹមតែធ្វើឱ្យស្ថានភាពសេរីភាពអ៊ីនធឺណិតកាន់តែអាក្រក់ឡើង និងសម្រាប់តែដើម្បីត្រួតពិនិត្យលើការផ្សព្វផ្សាយប៉ុណ្ណោះ។

នៅក្រោមមាត្រា ១៤ ប្រតិបត្តិករនៃច្រកទ្វារត្រូវតម្រូវឱ្យរក្សាទុកទិន្នន័យ និងផ្តល់របាយការណ៍ស្ថានភាពជាប្រចាំដល់អាជ្ញាធរមានសមត្ថកិច្ច។ តាមរយៈការរក្សាទុកកំណត់ត្រាបច្ចេកទេស តារាងបែងចែក

ការផ្តល់អាសយដ្ឋាន IP និងការកំណត់ផ្លូវនៃត្រាហ្វុងឆ្លងកាត់ តាមរយៈច្រកទ្វារអ៊ីនធឺណិតជាតិ សម្រាប់រយៈពេល ១២ ខែ ប្រតិបត្តិករអាចតាមដានសកម្មភាពរបស់អ្នកប្រើប្រាស់បាន។

អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិតបានរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពព័ត៌មាន ជាមួយនឹងឈ្មោះដែនណាមួយដែលរដ្ឋាភិបាលចាត់ទុកថាមិនអាចចុះឈ្មោះបាន និងមិនអាចចុះឈ្មោះឡើងវិញបានបន្ទាប់ពីការលុបចោលរួចទៅហើយ។ ត្រង់មាត្រា ៨ ចែងថា ការចុះឈ្មោះដែនជាតិត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍មកមុនបម្រើមុន។ ឈ្មោះដែនជាតិដែលមិនអាចចុះឈ្មោះបានរួមមានឈ្មោះដែនទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌ ប្រពៃណី និងសាសនា និងបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ យោងមាត្រា ១១ អ្នកចុះឈ្មោះដែនត្រូវមានកាតព្វកិច្ចជាអាទិ៍៖ មិនត្រូវប្រើឈ្មោះដែនជាតិដើម្បីផ្សព្វផ្សាយសកម្មភាព ឬពាណិជ្ជកម្ម ឬព័ត៌មានផ្សេងទៀត និងទំនាក់ទំនងតាមអ៊ីនធឺណិតដែលប៉ះពាល់ដល់វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍ផ្លូវច្បាប់សាធារណៈ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សង្គម។

## សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចុប្បន្នកំពុងបង្កើតច្បាប់ស្តីពីសន្តិសុខសាយប័រ ដើម្បីបង្កើតស្ថាប័នត្រួតពិនិត្យលើការគ្រប់គ្រងសន្តិសុខឌីជីថល និងពង្រីកសិទ្ធិអំណាចរបស់នគរបាលមានសមត្ថកិច្ច។ សេចក្តីព្រាងច្បាប់ដើមដំបូងមិនបានធានានូវឯករាជ្យភាពនៃស្ថាប័ននិយ័តកម្ម និងរួមបញ្ចូលមធ្យោបាយមិនគ្រប់គ្រាន់នៃការប្តឹងឧទ្ធរណ៍ទេ។ លើសពីនេះ វាផ្តល់សិទ្ធិក្នុងការស្វែងរក និងក្តោបយកយ៉ាងទូលំទូលាយក្នុងអំឡុងពេលមានឧប្បត្តិហេតុសន្តិសុខតាមអ៊ីនធឺណិតដែលបានកំណត់យ៉ាងធូររលុង ហើយវាក៏អនុញ្ញាតឱ្យមានការដាក់ទោសទណ្ឌចំពោះអ្នកដែលមិនគោរពតាមផងដែរ។ ច្បាប់នេះបានដាក់បន្ទុកយ៉ាងតឹងរ៉ឹងចំពោះបទល្មើសដែលប្រឈមនឹងការពិន័យព្រហ្មទណ្ឌ រួមទាំងការមិនគោរពតាមលក្ខខណ្ឌបច្ចេកទេសក្នុងការថែរក្សាសន្តិសុខតាមអ៊ីនធឺណិត ការខកខានក្នុងការរាយការណ៍អំពីឧប្បត្តិហេតុសន្តិសុខតាមអ៊ីនធឺណិត និងការផ្តល់សេវាសន្តិសុខតាមអ៊ីនធឺណិតដោយគ្មានអាជ្ញាប័ណ្ណ។ សេចក្តីព្រាងច្បាប់នេះ រួមមានការក្តោបយកបទប្បញ្ញត្តិទាំងអស់ ដែលបានក្លាយជាពាណិជ្ជសញ្ញានៃច្បាប់កម្ពុជាយ៉ាងឆាប់រហ័ស ដែលនឹងអនុញ្ញាតឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្ត "កាតព្វកិច្ចចាំបាច់ណាមួយទាក់ទងនឹងសន្តិសុខតាមអ៊ីនធឺណិត"។ ភាសាដ៏ទើសទាល់បែបនេះធ្វើឱ្យខូចដល់លក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃភាពស្របច្បាប់ និងបន្ថែមលើអំណាចច្បាប់ទូលំទូលាយរបស់រដ្ឋាភិបាល ដែលអាចប្រើប្រាស់ជាអាវុធប្រឆាំងនឹងក្រុមអ្នករិះគន់លើឆន្ទៈរបស់ខ្លួន។

## អនុក្រឹត្យស្តីពីការចុះឈ្មោះដែន

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ រដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យថ្មីមួយសំដៅគ្រប់គ្រងឈ្មោះដែន គឺ អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។ អនុក្រឹត្យនេះកំណត់ឱ្យប្រើប្រាស់ឈ្មោះដែនជាតិ (.kh) ដោយអង្គភាពទាំងអស់ដែលបានចុះបញ្ជិកាប្រតិបត្តិការក្នុងប្រទេសកម្ពុជា។ នៅខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបើកដំណើរការគេហទំព័រមួយ ដែលឈ្មោះដែនផ្លូវការទាំងឡាយអាចរកជាវបាន។ ខណៈពេលដែលរដ្ឋាភិបាលមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការគ្រប់គ្រងឈ្មោះដែនជាតិរបស់ខ្លួនដូច្នេះ ការទាមទារឱ្យប្រើប្រាស់ឈ្មោះដែនជាតិអាចដាក់កម្រិតសេរីភាពនៃការបញ្ចេញមតិដោយរំលោភលើស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ វាក៏ជាការព្រួយបារម្ភផងដែរដែលថា អនុក្រឹត្យកំណត់ឈ្មោះដែនអាចត្រូវបានប្រើដោយភ្ជាប់ជាមួយនឹងច្បាប់រឹតបន្តឹងផ្សេងទៀតស្តីពីការបញ្ចេញមតិ តាមប្រព័ន្ធអ៊ីនធឺណិត និងការគ្រប់គ្រងឌីជីថល ដើម្បីត្រួតពិនិត្យមាតិកាលើប្រព័ន្ធអ៊ីនធឺណិត និងបង្កើនការឃ្លាំ

មើលបន្ថែមទៀត។

## ករណីដែលបានរាយការណ៍អំពីការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត

រដ្ឋាភិបាលបានបញ្ជាឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតបិទខ្ទប់នូវគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមដែលជាបណ្តាញផ្សព្វផ្សាយឯករាជ្យមួយចំនួន ក៏ដូចជាមូលដ្ឋានទិន្នន័យសាធារណៈមួយចំនួនផងដែរ។[12]

កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣ សារព័ត៌មានអនឡាញ VOD បានចេញផ្សាយអត្ថបទមួយថា លោក ហ៊ុន ម៉ាណែត កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយហិរញ្ញវត្ថុដល់ប្រទេសតួកគី ដូចដែលបានអះអាងដោយលោក ផៃ ស៊ីផាន អ្នកនាំពាក្យរាជរដ្ឋាភិបាល។ បន្ទាប់មក លោក ហ៊ុន សែន បានប្រកាសនៅលើទំព័រហ្វេសប៊ុករបស់លោកថា VOD ត្រូវតែសុំទោសកូនប្រុសរបស់លោកក្នុងរយៈពេល ៧២ ម៉ោង បើមិនដូច្នេះទេ ក្រសួងព័ត៌មាននឹងដកហូតអាជ្ញាប័ណ្ណនៃសារព័ត៌មានមួយនេះតែម្តង។ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ VOD បានផ្ញើលិខិតមួយច្បាប់ជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសម្តែងការសោកស្តាយ និងសុំអភ័យទោសចំពោះកំហុសអចេតនាមួយនេះ។ ទោះជាយ៉ាងនេះក្តី លោកនាយករដ្ឋមន្ត្រីបានច្រានចោលការសុំទោសនៅព្រឹកព្រលឹមថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ហើយបន្ទាប់មកគេហទំព័រជាខេមរភាសា និងអង់គ្លេសរបស់ VOD ក៏ត្រូវបានបិទចោលទាំងស្រុងដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត។[13] នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានដកអាជ្ញាប័ណ្ណរបស់ VOD ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។[14]

យោងតាមសារព័ត៌មានចេញផ្សាយដោយ Bangkok Post បានឱ្យដឹងថា "ក្រុមប្រឹក្សាត្រួតពិនិត្យ ដែលជាក្រុមអ្នកសម្រេចចិត្ត កាលពីថ្ងៃព្រហស្បតិ៍ បានផ្តល់អនុសាសន៍ថា គណនី Facebook និង Instagram របស់លោក ហ៊ុន សែន ត្រូវផ្អាករយៈពេលប្រាំមួយខែ ដោយសារខ្សែវីដេអូដែលបានថតកាលពីខែមករា ដែលលោកបានប្រាប់ក្រុមអ្នកប្រឆាំងថាពួកគេនឹងប្រឈមមុខចំពោះវិធានការផ្លូវច្បាប់ ឬនឹងត្រូវវាយនឹងដំបងប្រសិនបើពួកគេចោទគណបក្សរបស់គាត់ថាបានលួចសន្លឹកឆ្នោតក្នុងការបោះឆ្នោតជាតិ កាលពីខែកក្កដាកន្លងទៅ។ បច្ចុប្បន្ន "លោកនាយករដ្ឋមន្ត្រីកម្ពុជាប្រើប្រាស់កម្មវិធី Telegram ដើម្បីបញ្ជូនសារនយោបាយរបស់គាត់ទៅកាន់ក្រុមអ្នកគាំទ្រ និងកម្មវិធី TikTok ដើម្បីចូលរួមជាមួយក្រុមយុវជន។"[15]

លើសពីនេះ ក្រសួងព័ត៌មានក៏បានដកអាជ្ញាប័ណ្ណរបស់ប្រព័ន្ធផ្សព្វផ្សាយចំនួនបីផ្សេងទៀតផងដែរ បន្ទាប់ពីមានសេចក្តីរាយការណ៍អំពីការជាប់ពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់ក្នុងការក្លែងបន្លំបញ្ហាដីធ្លី។ បណ្តាញសារព័ត៌មានទាំងនេះរួមមានសហព័ន្ធអ្នកកាសែតកម្ពុជា-អាស៊ាន រស្មីកំពង់ចាម និងដំណឹងក្នុង Federation of Cambodia-ASEAN Journalists, Raksmey Kampong Cham, and Dumnong Knong.។[16]

---

[12] https://cambojanews.com/government-orders-internet-providers-to-block-media-outlets-kamnotra-database/

[13] https://www.licadho-cambodia.org/articles/20230213/180/index.html

[14] Sochan, R. (2023, February 13). VOD's media licence revoked. VOD's Media Licence Revoked | Phnom Penh Post. https://phnompenhpost.com/national/vods-media-licence-revoked

[15] Public Company Limited, B. P. (n.d.). *Cambodia's Hun Sen threatens to block Facebook access.* https://www.bangkokpost.com. https://www.bangkokpost.com/world/2602683/cambodias-hun-sen-threatens-to-block-facebook-access

[16] *Information Ministry Revokes Three Media Licenses Following Reports on Senior Official’s Role in Land Fraud | CamboJA News*. (2023, March 18). Information Ministry Revokes Three Media Licenses Following Reports on Senior Official&Rsquo;S Role in Land Fraud | CamboJA News.

# ទិដ្ឋភាពបណ្ដាញ

តាមរយៈទំនាក់ទំនងដ៏រឹងមាំរបស់ខ្លួនជាមួយ និងមានឥទ្ធិពលលើក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិត (ISPs) រដ្ឋាភិបាលបានពង្រីកការគ្រប់គ្រងរបស់ខ្លួននៅលើប្រព័ន្ធអ៊ីនធឺណិត។ តាមការបញ្ជាក់ សេរីភាពអ៊ីនធឺណិតនៅប្រទេសកម្ពុជាកំពុងស្ថិតក្រោមការគំរាមកំហែងកាន់តែខ្លាំងឡើងៗ។ ក្រុមហ៊ុនទូរគមនាគមន៍ធំៗចំនួនប្រាំដែលផ្ដល់សេវាអ៊ីនធឺណិតក្រោមដី និងតាមទូរសព្ទចល័តក្នុងប្រទេសកម្ពុជា រួមមានក្រុមហ៊ុន Viettel ក្រុមហ៊ុន Smart Axiata ក្រុមហ៊ុន CamGSM ក្រុមហ៊ុន Xinwei Telecom និងក្រុមហ៊ុន Southeast Asia Telecom មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលកម្ពុជា និងក្រុមមន្ត្រីរបស់ខ្លួន ហើយពួកគេទំនងជាផ្ដល់ការគ្របដណ្ដប់ដល់គ្នាទៅវិញទៅមក។

ឧបករណ៍ទំនាក់ទំនងសំខាន់ៗនៅក្នុងប្រទេសកម្ពុជាមានចំនួនបីគឺ ទូរសព្ទចល័ត ទូរសព្ទភ្ជាប់ខ្សែ និងប្រព័ន្ធអ៊ីនធឺណិត។ យោងតាមនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) ដែលទើបតែដំណើរការថ្មីថ្មោងបានឱ្យដឹងថាចំនួនអ្នកចុះឈ្មោះប្រើសេវាទាំងនេះ the numbers of subscribers for these services មានដូចជា៖

## ចំនួនចុះឈ្មោះប្រើប្រាស់ទូរសព្ទចល័ត

| Year | Subscribers |
|---|---|
| 2016 | 19915503 |
| 2017 | 18572973 |
| 2018 | 19417123 |
| 2019 | 21675523 |
| 2020 | 20827435 |
| 2021 | 19899790 |
| 2022(Sep) | 19595983 |




គំនូសតាងទី ១៖ តារាងបង្ហាញចំនួនអ្នកចុះឈ្មោះប្រើប្រាស់ទូរសព្ទចល័យតាមឆ្នាំនីមួយៗ។ ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ក្នុងឆ្នាំ២០២០ ចំនួនអ្នកប្រើប្រាស់បានកើនឡើងយ៉ាងខ្លាំងដល់ទៅចំនួន ២០,៨២៧,៤៣៥ នាក់។ នៅពេលដែលស្ថានភាពជំងឺរាតត្បាតកូវីដ-១៩ មានភាពធូរស្រាលឡើងវិញ ចំនួនអ្នកប្រើប្រាស់បានថយចុះបន្តិចបន្តួចក្នុងឆ្នាំ២០២១ (ចំនួន ១៩,៨៩៩,៧៩០ នាក់) និងនៅខែកញ្ញា ឆ្នាំ២០២២ (ចំនួន ១៩,៥៩៥,៩៨៣ នាក់)។

ប្រភព៖ Telecommunication Regulators of Cambodia

---

https://cambojanews.com/information-ministry-revokes-three-media-licenses-following-reports-on-senior-officials-role-in-land-fraud/

## ចំនួនចុះឈ្មោះប្រើប្រាស់ទូរសព្ទភ្ជាប់ខ្សែ

| Year | Subscribers |
|---|---|
| 2016 | 227261 |
| 2017 | 132911 |
| 2018 | 88157 |
| 2019 | 57438 |
| 2020 | 49381 |
| 2021 | 40296 |
| 2022(SEP) | 38875 |




គំនូសតាងទី 2៖ ចំនួនចុះឈ្មោះប្រើប្រាស់ទូរសព្ទភ្ជាប់ខ្សែនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៦ (ចំនួនចុះឈ្មោះប្រើប្រាស់ ២២៧២៦១ នាក់) ដល់ខែកញ្ញា ឆ្នាំ២០២២ (ចំនួន ៣៨៨៧៥ នាក់)។ ចំនួនចុះឈ្មោះប្រើប្រាស់ ក្នុងឆ្នាំ២០១៧ (ចំនួនចុះឈ្មោះប្រើប្រាស់ ១៣២៩១១ នាក់) បានធ្លាក់ចុះជិតពាក់កណ្តាលនៃឆ្នាំ២០១៦ (ចំនួនចុះឈ្មោះប្រើប្រាស់ ២២៧២៦១ នាក់)។ ការធ្លាក់ចុះទាបបំផុតគឺនៅចន្លោះឆ្នាំ២០២១ (ចំនួន ៤០២៩៦ នាក់) និងឆ្នាំ២០២២ (ចំនួន ៣៨៨៧៥ នាក់)។

## ចំនួនចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិត

| Year | Subscribers |
|---|---|
| 2016 | 8099132 |
| 2017 | 10649370 |
| 2018 | 13611398 |
| 2019 | 16126356 |
| 2020 | 20340480 |
| 2021 | 17872173 |
| 2022(SEP) | 18008225 |




គំនូសតាងទី 3៖ ចំនួនអ្នកចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិតនៅខែកញ្ញា ឆ្នាំ២០២២ (ចំនួន ១៨,០០៨,២២៥) បានកើនឡើងច្រើនជាងពីរដងធៀបនឹងឆ្នាំ២០១៦ (ចំនួន ៨,០៩៩,១៣២ នាក់)។ ចំនួនចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិតខ្ពស់បំផុតគឺនៅឆ្នាំ២០២០ (ចំនួន ២០,៣៤០,៤៨០ នាក់) អំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។ បន្ទាប់មកវាបានថយចុះបន្តិចបន្តួចក្នុងឆ្នាំ២០២១ (ចំនួន ១៧,៨៧២,១៧៣) និងកើនឡើងបន្តិចបន្តួចនៅឆ្នាំ២០២២ (ចំនួន ១៨,០០៨,២២៥)។

ប្រភព៖ Telecommunication Regulators of Cambodia

# ចំនួនអាជ្ញាប័ណ្ណ

| ល.រ | អាជ្ញាប័ណ្ណ | សរុប |
|---|---|---|
| ១ | ច្រកទ្វារអន្តរជាតិ | ២ |
| ២ | ទូរសព្ទចល័ត | ៥ |
| ៣ | ទូរសព្ទភ្ជាប់ខ្សែ | ៦ |
| ៤ | ប្រព័ន្ធ VoIP | ៩ |
| ៥ | ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) | ៤២ |
| ៦ | ផ្កាយរណប | ១ |
| ៧ | ប្រព័ន្ធចែករំលែកទូរគមនាគមន៍តាមអគារ | ៤ |
| ៨ | ខ្សែកាបក្រោមបាតសមុទ្រ | ២ |
| ៩ | បណ្តាញខ្សែកាបអុបទិក | ៥ |
| ១០ | បណ្តាញបន្ថែមតម្លៃ | ១ |
| ១១ | ប្រព័ន្ធទូរសព្ទឥតគិតថ្លៃ | ១ |

តារាងទី 2៖ អាជ្ញាប័ណ្ណទាំងនេះបានធ្វើការរួមគ្នាដើម្បីផ្តល់សេវាអ៊ីនធឺណិត និងការហៅទូរសព្ទទៅកាន់អ្នកប្រើប្រាស់។

ប្រភព៖ TelecommunicationRegulatorsofCambodia

# ក្រុមហ៊ុនទូរសព្ទចល័ត

| ល.រ | បណ្តាញ | ក្រុមហ៊ុន |
|---|---|---|
| ១ | Smart | Smart Axiata Co., Ltd |
| ២ | Mobitel/ CellCard | CamGSM Co., Ltd. |
| ៣ | CooTel | Xinwei (Cambodia) Telecom Co., Ltd |
| ៤ | SEATEL | Southeast Asia Telecom (Cambodia) Co., Ltd. |
| ៥ | Metfone | Viettel (Cambodia) Pte., Ltd. |

តារាងទី 3៖ យោងតាម TRC បានឱ្យដឹងថាក្រុមហ៊ុនចំនួនបី (Metfone, Cellcard, និង Smart) ក្នុងចំណោមក្រុមហ៊ុនទូរគមនាគមន៍ទាំងប្រាំ មានចំនួន៩០% នៃអ្នកប្រើប្រាស់សរុប។ ក្រុមហ៊ុន Metfone មានសេវាគ្របដណ្តប់ធំបំផុតលើទិន្នន័យទូរសព្ទចល័ត និងការប្រើប្រាស់អ៊ីនធឺណិត ប៉ុន្តែក្រុមហ៊ុន Cellcard បានឈ្នះពានរង្វាន់ Ookla Speed Test Award សម្រាប់រយៈពេល ៤ ឆ្នាំជាប់គ្នា ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២០។ ចំណែកឯក្រុមហ៊ុន Smart ទទួលបានកេរ្តិ៍ឈ្មោះល្បីតាមរយៈការលើកកម្ពស់ការចាប់ផ្តើមអាជីវកម្មបច្ចេកវិទ្យាក្នុងចំណោមយុវជន និងមនុស្សវ័យជំទង់។ ជាពិសេសក្រុមហ៊ុន Cellcard និងក្រុមហ៊ុន Smart បានផ្តល់ជូននូវការផ្សព្វផ្សាយជាច្រើនដូចជាកីឡាអេឡិចត្រូនិក និងហ្គេមអេឡិចត្រូនិក ដែលទទួលបានការចាប់អារម្មណ៍ច្រើនពីទស្សនិកជនវ័យក្មេង។

ប្រភព៖ Telecommunication Regulators of Cambodia

## ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ( ISP )

ក្រុមហ៊ុនផ្តល់សេវាអ៊ីនអឺណិត មានចំនួនប្រហែល ៤២ បាននិងកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយបានអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ក្នុងចំណោមក្រុមហ៊ុនទូរគមនាគមន៍ធំៗទាំងប្រាំនេះ សុទ្ធតែផ្តល់សេវាអ៊ីនធឺណេតតាមទូរសព្ទចល័ត និងខ្សែកាបក្រោមដី៖ ក្រុមហ៊ុន Viettel ក្រុមហ៊ុន Smart Axiata ក្រុមហ៊ុន CamGSM ក្រុមហ៊ុន Xinwei Telecom និងក្រុមហ៊ុន Southeast Asia Telecom ដែលសុទ្ធតែមានប្រភពមកពីប្រទេសកាន់អំណាចផ្តាច់ការ។ Viettel ជាក្រុមហ៊ុនវៀតណាមដែលគ្រប់គ្រងដោយក្រសួងការពារជាតិវៀតណាម ប្រតិបត្តិការនៅកម្ពុជាក្រោមឈ្មោះថា Metfone។ ក្រុមហ៊ុន CamGSM ត្រូវបានគេស្គាល់ដំបូងថា Mobitel មុនពេលប្តូរស្លាកសញ្ញាទៅជា Cellcard ក្នុងឆ្នាំ២០០៥។

ក្រុមហ៊ុន Viettel ក្រុមហ៊ុន Smart Axiata និងក្រុមហ៊ុន CamGSM ក្នុងស្រុកមានចំណែកទីផ្សារប្រហែល ៩០% នៃចំនួនចុះឈ្មោះប្រើប្រាស់ទូរសព្ទចល័ត។ ក្រុមហ៊ុន Smart Axiata ទទួលបានចំណែកទីផ្សារជិត ៦០% ខណៈដែលក្រុមហ៊ុន Viettel ទទួលបានចំណែកទីផ្សារ ២៦% ហើយក្រុមហ៊ុន CamGSM ទទួលបាន ១១%។ ក្រុមហ៊ុន Xinwei Telecom មកពីប្រទេសចិនដែលប្រតិបត្តិការក្រោមឈ្មោះថា CooTel មានចំណែកទីផ្សារ ២.៦៧% រីឯក្រុមហ៊ុន Southeast Asia Telecom មកពីប្រទេសសិង្ហបុរី មានចំណែកទីផ្សារ ០.៦៥%។[17] ដោយឡែកក្រុមហ៊ុន Metfone ផ្តល់សេវាកម្មគ្រប់ប្រភេទ (ការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណែត ការជួលបណ្តាញ ការជួលសៀគ្វីឯកជន សេវាផ្ញើសារ និងសំឡេងតាមទូរសព្ទចល័ត និងប្រព័ន្ធ ADSL) ខណៈពេលដែលក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតផ្សេងទៀត ក៏បានផ្តល់សេវាកម្មមួយចំនួនផ្សេងទៀតក្នុងចំណោមសេវាកម្មទាំងនេះផងដែរ។ ឈ្មោះលម្អិតនៃក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំង ៤២ ត្រូវបានរាយបញ្ជីក្នុងឧបសម្ព័ន្ធ III ។

## វិញ្ញាបនបត្រ




គំនូសតាងទី 4៖ ចំនួនសរុបនៃការចុះឈ្មោះដែនក្នុងស្រុកពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ គឺមានចំនួន ២០,៣១០ ដែន។ ចំនួនខ្ពស់បំផុត (៣,៨៧២ ដែន) គឺនៅឆ្នាំ២០២០។ ការចុះឈ្មោះតាមហាងអ៊ីនធឺណែតសរុបចំនួន ៥៦២ ទីតាំង ហើយចំនួនខ្ពស់បំផុតគឺ ២៥១ ទីតាំង កាលពីឆ្នាំ២០១៧។

[17] Asia Centre. (2021). Internet Freedoms in Cambodia: A Gateway To Control. https://asiacentre.org/wp-content/uploads/Internet-Freedoms-in-Cambodia-A-Gateway-to-Control.pdf

| វិញ្ញាបនបត្រ | | | |
|---|---|---|---|
| ល.រ | ឆ្នាំ | ហាងអ៊ីនធឺណិត | ឈ្មោះដែន (.kh) |
| ១ | ២០១៧ | ២៥១ | ៣២១០ |
| ២ | ២០១៨ | ១៣៥ | ៣២២៦ |
| ៣ | ២០១៩ | ១១១ | ៣៧១៨ |
| ៤ | ២០២០ | ៣៦ | ៣៨៧២ |
| ៥ | ២០២១ | ២០ | ៣០២៩ |
| ៦ | ២០២២ (ខែវិច្ឆិកា) | ៩ | ៣២៥៥ |

តារាងទី ៤៖ ហាងអ៊ីនធឺណែត និងឈ្មោះដែនក្នុងស្រុក (.KH) ដែលបានចុះឈ្មោះប្រចាំឆ្នាំ។
ប្រភព៖ Telecommunication Regulators of Cambodia

## ការផ្ញើសារផ្លាស់ៗ

| ឆ្នាំ (លាន) | Facebook | Instagram | TikTok | LinkedIn |
|---|---|---|---|---|
| មករា ឆ្នាំ២០២៣ | ១១.៧៥ លាន | ១.៨៤ លាន | ៧.៤ លាន | ០.៥០ លាន |
| កើនឡើង | ០.៩១% | ០.៩១% | ១.២១% | ១.១២% |

តារាងទី 5៖ វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម Tiktok មានការកើនឡើង (១.២១%) ច្រើនជាងចំនួនគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀតដូចជា Facebook (០.៩១%), Instagram (០.៩១%) និង LinkedIn (១.១២%)។[18]

## លទ្ធផលរកឃើញនៃការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតនៅប្រទេសកម្ពុជា

គម្រោងតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI) សហការជាមួយគម្រោង Sinar និងវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) មជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និងសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) បានធ្វើការសិក្សាអំពីការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃការសិក្សានេះ គឺដើម្បីស្វែងយល់ថាតើនិងកម្រិតណាដែលការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតបានកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលធ្វើតេស្តចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

---

18 *Social Media in Cambodia - 2023 Stats & Platform Trends - OOSGA*. (n.d.). OOSGA. https://oosga.com/social-media/khm/

# ការបិទខ្ទប់គេហទំព័រ

ក្នុងរយៈពេលពេញមួយឆ្នាំ យើងបានធ្វើតេស្តការវាស់វែងចំនួន ២.៥ លាន ចេញពីគេហទំព័រចំនួន ២,២០១ នៅលើគម្រោង OONI ។ គិតមកត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មានគេហទំព័រចំនួន ១,៦២៩ នៅក្នុងបញ្ជីគេហទំព័រសកល និង ៨៣ នៅក្នុងបញ្ជីគេហទំព័រខ្មែរ។ ដោយផ្អែកលើការវាស់វែងនៃគម្រោង OONI ជាទូទៅនៅក្នុងរបាយការណ៍នេះ យើងនឹងប្រើបច្ចេកសព្ទដូចខាងក្រោម៖

- **ចំនួនដែលបានវាស់វែង ឬការវាស់វែង**៖ សំដៅលើចំនួនសរុបនៃការវាស់វែងដែលប្រមូលបានតាមរយៈកម្មវិធី OONI Probe ។
- **ការបិទខ្ទប់**៖ សំដៅលើ "បានបញ្ជាក់ថាបិទខ្ទប់" នៅក្នុងការវាស់វែងនៃ OONI ដែលជាការវាស់វែងពីគេហទំព័រដែលត្រូវបានបិទខ្ទប់ដោយស្វ័យប្រវត្តិ (ឧ. ទំព័រប្លុកត្រូវបានបម្រើ)។
- **ទំនងជាត្រូវបានបិទខ្ទប់ (បិទ)**៖ សំដៅលើ "ភាពមិនប្រក្រតី" និង "ការបរាជ័យ" នៅក្នុងការវាស់វែងនៃ OONI។ ភាពមិនប្រក្រតីគឺជាការវាស់វែងដែលបង្ហាញសញ្ញានៃការបិទខ្ទប់សក្តានុពល ប៉ុន្តែទោះយ៉ាងណាក៏ដោយ ភាពវិជ្ជមានមិនពិត false positives អាចកើតឡើង។ ការបរាជ័យសំដៅទៅលើការពិសោធន៍ដែលបរាជ័យក្នុងការធ្វើតេស្ត OONI ទោះបីជាពេលខ្លះវាអាចជាសញ្ញានៃការត្រួតពិនិត្យពិរុទ្ធភាពក៏ដោយ symptomatic of censorship (លើកលែងតែនៅក្នុងប្រទេសឥណ្ឌា)។
- **បញ្ចូល**៖ ចំនួនគេហទំព័រដែលត្រូវបានធ្វើតេស្ត។
- **លេខប្រព័ន្ធស្វយ័តភាព (ASN)**៖ ជាឧបករណ៍កំណត់អត្តសញ្ញាណតែមួយគត់ដែលមាននៅទូទាំងពិភពលោក និងអនុញ្ញាតឱ្យប្រព័ន្ធស្វយ័តភាពផ្ទាល់ខ្លួនផ្លាស់ប្តូរចរន្តព័ត៌មានជាមួយប្រព័ន្ធផ្សេងទៀត។ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) ចាំបាច់ត្រូវចុះឈ្មោះអត្តសញ្ញាណនៃលេខប្រព័ន្ធស្វយ័តភាព (ASN) ដើម្បីកំណត់អត្តសញ្ញាណបណ្តាញ។

| | កក្កដា-កញ្ញា ២០២២ | តុលា-ធ្នូ ២០២២ | មករា-មីនា២០២៣ | មេសា-មិថុនា២០២៣ | សរុប |
|---|---|---|---|---|---|
| បានវាស់វែង | 405,134 | 563,309 | 773,357 | 788,627 | 2,530,427 |
| បានបិទខ្ទប់ | 0 | 0 | 243 | 964 | 1,236 |
| អត្រាបិទខ្ទប់ | 0.00% | 0.00% | 0.03% | 0.12% | 0.05% |
| បានបញ្ចូល (គេហទំព័រ) | 1,886 | 1,798 | 1,837 | 1,870 | 2,201 |
| ASNs (ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត) | 14 | 19 | 18 | 22 | 24 |

តារាងទី ៦៖ សេចក្តីសង្ខេបនៃការវាស់វែងការតភ្ជាប់បណ្តាញ OONI សម្រាប់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

ចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣ មានគេហទំព័រចំនួន ២,២០១ ដែលបានវាស់វែងដោយ OONI Probe ។ លទ្ធផលបានបង្ហាញថា នៅកម្ពុជាមានគេហទំព័រចំនួន ៣៧ (គេហទំព័រសកលចំនួន ២២ និងគេហទំព័រខ្មែរចំនួន ១៥) ក្នុងចំណោមគេហទំព័រសរុបចំនួន ២,២០១ ដែលត្រូវបានបិទខ្ទប់ ឬត្រួតពិនិត្យពិរុទ្ធភាពដោយប្រព័ន្ធ DNS ពីសំណាក់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (Viettel, Ezecom, Wicam, CamSIM, Private Company (iSEEK)) ដោយប្រើវិធីសាស្រ្តបិទខ្ទប់ដោយការរាំងនៃប្រព័ន្ធ DNS ដែលគេហទំព័រនេះនឹងត្រូវបានបញ្ជូនបន្តទៅកាន់អាសយដ្ឋាន IP ដែលផុតម៉ោងកំណត់ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ឬអាសយដ្ឋាន IP bogon នៃ 127.0.0.1 ។ សារព័ត៌មានល្បីៗមួយចំនួនក៏ត្រូវបានរកឃើញថាត្រូវបានគេត្រួតពិនិត្យពិរុទ្ធភាពផងដែរដូចជា វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) វិទ្យុអាស៊ីសេរី (RFA) និងខេមបូឌា ដេលី ជាដើម។

ក្នុងចំណោមគេហទំព័រទាំង ៣៧ ដែលត្រូវបានបិទខ្ទប់ ឬត្រួតពិនិត្យពិរុទ្ធភាព គេបានរកឃើញថាដែន ឬគេហទំព័រមួយចំនួននៅតែសកម្មជាធម្មតា (១២ គេហទំព័រ) ចុះ/មិនអាចចូលប្រើបាន (១៨ គេហទំព័រ) ឬដាក់លក់ (៧ គេហទំព័រ)។ ដែនដែលត្រូវបានបិទខ្ទប់និងលក់បន្ត នៅតែត្រូវបានបន្តបិទខ្ទប់ដដែល ទោះបីជាគេហទំព័រទាំងនេះនឹងសកម្មជាធម្មតា ប្រសិនបើក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) នឹងមិនដកវាចេញពីបញ្ជីត្រួតពិនិត្យពិរុទ្ធភាពក៏ដោយ។

គេហទំព័រពេញនិយមមួយចំនួន និងដែនរងខ្លះដែលត្រូវបានបោះបង់ចោលអស់រយៈពេលជាច្រើនឆ្នាំនៅតែត្រូវបានត្រួតពិនិត្យពិរុទ្ធភាពដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត។

- http://khmer.cambodiadaily.com/ និង https://khmer.cambodiadaily.com/ គឺជាអតីតដែនរងរបស់អង្គភាពសារព័ត៌មានខេមបូឌា ដេលី ដេលី ចំណែកគេហទំព័រផ្លូវការបច្ចុប្បន្នគឺ https://www.cambodiadaily.com/

ការវាស់វែងទាំងនេះត្រូវបានវិភាគដោយប្រើវិធីសាស្រ្តស្វែងរកទិន្នន័យលំអិត ដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ IV ។ គេបានរកឃើញថាមានគេហទំព័រសរុបចំនួន ៣៧ ដែលត្រូវបានបញ្ជាក់ថាត្រូវបានបិទខ្ទប់ ដែលក្នុងនោះ ២៣ គេហទំព័រត្រូវបានបញ្ជាក់ដោយ OONI និង ១៤ ទៀតត្រូវបានបញ្ជាក់ដោយការស្ទង់មតិ និងរបាយការណ៍ព័ត៌មានរួមនឹងការវាស់វែងរបស់ OONI ។ ឧបសម្ព័ន្ធ I បញ្ជាក់ព័ត៌មានលម្អិតអំពីគេហទំព័រដែលត្រូវបានបិទខ្ទប់៖

- ឈ្មោះគេហទំព័រ
- ឈ្មោះក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត
- វិធីសាស្រ្តនៃការបិទខ្ទប់
- រយៈពេលនៃការបិទខ្ទប់
- ស្ថានភាពគេហទំព័រ
- ប្រភពដើម (មិនថាវាជាគេហទំព័រសកល ឬជាគេហទំព័រខ្មែរ)។

| ប្រភេទ | បរិយាយប្រភេទ | ការវាស់វែង OONI Probe | ចំនួនការវាស់វែងដែលបានបិទខ្ទប់ និងទំនងជាត្រូវបានបិទខ្ទប់ | ភាគរយនៃការវាស់វែងដែលបានបិទខ្ទប់ និងទំនងជាត្រូវបានបិទខ្ទប់ |
|---|---|---|---|---|
| ALDR | គ្រឿងស្រវឹង និងគ្រឿងញៀន | 27,589 | 451 | 1.6% |
| ANON | ឧបករណ៍អនាមិក និង ឧបករណ៍បញ្ចៀស | 155,093 | 8,510 | 5.5% |
| COMM | ពាណិជ្ជកម្មអេឡិចត្រូនិច | 14,984 | 275 | 1.8% |
| COMT | ឧបករណ៍ទំនាក់ទំនង | 169,321 | 3,240 | 1.9% |
| CTRL | ការគ្រប់គ្រងមាតិកា | 17,254 | 66 | 0.4% |
| CULTR | វប្បធម៌ | 65,725 | 1,007 | 1.5% |
| DATE | កាលបរិច្ឆេទលើបណ្តាញ | 18,985 | 1,939 | 10.2% |
| ECON | សេដ្ឋកិច្ច | 28,461 | 1,834 | 6.4% |
| ENV | បរិស្ថាន | 54,612 | 705 | 1.3% |
| FILE | ការចែករំលែកឯកសារ | 57,932 | 2,718 | 4.7% |
| GAME | ហ្គេមកំសាន្ត | 18,059 | 110 | 0.6% |
| GMB | ល្បែងស៊ីសង | 24,211 | 1,700 | 7.0% |
| GOVT | រដ្ឋាភិបាល | 28,656 | 3,018 | 10.5% |
| GRP | ទំនាក់ទំនងបណ្តាញសង្គម | 238,831 | 3,486 | 1.5% |
| HACK | ឧបករណ៍លួចចូល | 28,958 | 2,486 | 8.6% |
| HATE | ពាក្យសម្តីស្អប់ខ្ពើម | 6,906 | 194 | 2.8% |
| HOST | វេទិកាបង្ហោះ និងប្លុក | 139,097 | 5,114 | 3.7% |
| HUMR | បញ្ហាសិទ្ធិមនុស្ស | 274,649 | 10,251 | 3.7% |
| IGO | អង្គការអន្តររដ្ឋាភិបាល | 7,230 | 46 | 0.6% |
| LGBT | អ្នកស្រលាញ់ភេទដូចគ្នា | 123,863 | 3,732 | 3.0% |
| MILX | អំពើភេរវកម្ម និងពួកសកម្ម | 3,487 | 61 | 1.7% |
| MISC | មាតិកាផ្សេងៗ | 4,005 | 20 | 0.5% |
| MMED | ការចែករំលែកប្រព័ន្ធ | 110,189 | 2,729 | 2.5% |
| NEWS | សារព័ត៌មាន | 570,739 | 26,182 | 4.6% |
| POLR | ការរិះគន់នយោបាយ | 54,409 | 3,691 | 6.8% |
| PORN | ភាពអាសអាភាស | 15,187 | 1,159 | 7.6% |
| PROV | ការស្លៀកពាក់មិនសមរម្យ | 12,764 | 120 | 0.9% |
| PUBH | សុខភាពសាធារណៈ | 68,650 | 1,423 | 2.1% |
| REL | សាសនា | 60,415 | 3,344 | 5.5% |
| SRCH | ម៉ាស៊ីនស្វែងរក | 44,909 | 1,812 | 4.0% |
| XED | ការអប់រំផ្លូវភេទ | 32,889 | 1,291 | 3.9% |

តារាងទី 7៖ សេចក្តីសង្ខេបនៃការវាស់វែងការតភ្ជាប់បណ្តាញ OONI សម្រាប់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ តាមប្រភេទ

## គេហទំព័រដែលបានបញ្ជាក់ថាត្រូវបានបិទខ្ទប់តាមប្រភេទ

លេខ និងភាគរយសម្រាប់គេហទំព័រទាំង ៣៧ ដែលត្រូវបានបិទខ្ទប់ ត្រូវបានបង្ហាញជាចំណាត់ថ្នាក់តាមប្រភេទ។ តម្លៃលេខក្រហម គឺជាភាគរយនៃគេហទំព័រដែលត្រូវបានបិទខ្ទប់ ហើយតម្លៃលេខខ្មៅ គឺជាចំនួនគេហទំព័រដែលត្រូវបានបិទខ្ទប់តាមប្រភេទ។




គំនូសតាងទី 5៖ ភាគរយខ្ពស់បំផុតនៃប្រភេទដែលត្រូវបានបិទខ្ទប់ គឺគេហទំព័រព័ត៌មាន (ចំនួន ១៣ គេហទំព័រ ឬ ស្មើ ៣៥.១%) និងទីពីរគឺគេហទំព័រផ្សេងៗ (ចំនួន ៤ គេហទំព័រ ឬស្មើ ១០.៨%)

## ការបិទខ្ទប់គេហទំព័រព័ត៌មាន

កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ គេហទំព័រព័ត៌មានឯករាជ្យមួយចំនួនត្រូវបានគេរាយការណ៍ថាត្រូវបានបិទខ្ទប់ a number of independent news websites were reportedly blocked ជាពិសេសគេហទំព័ររបស់វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) បន្ទាប់ពីសារព័ត៌មាននេះត្រូវបានបិទទាំងស្រុង វិទ្យុអាស៊ីសេរី និងខេមបូឌា ដេលី។

សរុបមក ដែនចំនួនប្រាំពីរត្រូវបានរកឃើញត្រូវបានគេបិទខ្ទប់ដោយផ្អែកលើការវាស់វែងនៃ OONI ។ វិធីសាស្ត្របិទខ្ទប់ទូទៅបំផុតគឺការរារាំងនៃប្រព័ន្ធ DNS ដែលគេហទំព័រនោះនឹងត្រូវបានបញ្ជូនបន្តទៅអាសយដ្ឋាន IP bogon នៃ 127.0.0.1 ។




គំនូសតាងទី 6៖ ការបិទខ្ទប់គេហទំព័រព័ត៌មាននៅប្រទេសកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ២០២៣ (ប្រភព៖ OONIExplorer)

## ការបិទខ្ទប់កម្មវិធីផ្ញើសារភ្លាមៗ

| កម្មវិធី | Facebook Messenger | Signal | Telegram | Whatsapp |
|---|---|---|---|---|
| សរុបការវាស់វែង | ២៥,៣១៤ | ១៦,៧២១ | ២៥,២៨១ | ២៥,៣២៣ |
| ភាគរយនៃការបិទខ្ទប់ និង ទំនងជាត្រូវបានបិទខ្ទប់ | 0.៨% | 0.៦% | 0.៥% | 0.៣% |

តារាងទី ៨៖ ការវាស់វែងនៃ OONI លើកម្មវិធីផ្ញើសារភ្លាមៗក្នុងប្រទេសកម្ពុជា ចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣

*កំណត់ចំណាំ៖*

- *ការវាស់វែងដែលបរាជ័យត្រូវបានលុបចោលពីតារាងនេះ។*
- *ដោយសារការអាប់ដេតលើកម្មវិធីទាំងនេះហួសពីសមត្ថភាពគ្រប់គ្រងរបស់ OONI ហើយកម្មវិធី OONI អាចជួបប្រទះនឹងបញ្ហាក្នុងការធ្វើតេស្ត ដោយសារការផ្លាស់ប្តូរដែលកើតឡើងពីមួយពេលទៅមួយពេល។ ដូច្នេះ ការវាស់វែងដែលបរាជ័យ ឬភាពមិនប្រក្រតីដែលត្រូវបានកំណត់ថាជាវិជ្ជមានមិនពិតត្រូវបានលុបចោលពីតារាងនេះ។ ដោយឡែក ការវាស់វែងដែលបានលុបចោលគឺបានមកពីការធ្វើតេស្តស៊ីញ៉ាលចាប់ពីថ្ងៃទី ៤-៣០ ខែឧសភា ឆ្នាំ២០២៣។*

# ការបិទខ្ទប់ឧបករណ៍បញ្ចៀស

| កម្មវិធី | PSIPHON | Tor | Tor Snowflake | Vanilla Tor |
|---|---|---|---|---|
| **សរុបការវាស់វែង** | ២៥,៣៧២ | ២៥,០៦៨ | ១៨,២៨០ | ១៨,០៧១ |
| **ភាគរយនៃការបិទខ្ទប់ និង ទំនងជាត្រូវបានបិទខ្ទប់** | 0.៧% | ២.២% | ១៣.៦% | 0.0% |

តារាងទី ១៖ ការវាស់វែងនៃ OONI លើឧបករណ៍បញ្ចៀសនៅក្នុងប្រទេសកម្ពុជាចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣

*ចំណាំ៖ ការវាស់វែងដែលបរាជ័យត្រូវបានលុបចោលពីតារាងនេះ។*

# ការទទួលស្គាល់ភាពមានកំរិត

- **រយៈពេលសិក្សា**

លទ្ធផលនៃការសិក្សានេះ ត្រូវបានដាក់កម្រិតចំពោះការវាស់វែងបណ្តាញដែលប្រមូលបានចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីពិនិត្យមើលលើនិន្នាការ និងព្រឹត្តិការណ៍នៃការត្រួតពិនិត្យពិរុទ្ធភាពថ្មីៗបំផុត។

- **ទីតាំងវាស់វែង**

ទោះបីជាមានការវាស់វែងបណ្តាញដែលបានប្រមូលពីទីតាំងទាំង២៤ នៅក្នុងប្រទេសកម្ពុជាក៏ដោយ ការធ្វើតេស្តដោយប្រើកម្មវិធី OONI មិនដំណើរការជាប់លាប់នៅគ្រប់បណ្តាញទាំងអស់នោះទេ។ ដោយសារតែបញ្ហានេះ លទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះ ជាពិសេសការបិទខ្ទប់ដែលបានបញ្ជាក់ ទំនងជាមិនបង្ហាញពីការបិទខ្ទប់ទាំងអស់ដែលធ្វើឡើងដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតនៅក្នុងប្រទេសនោះទេ។

- **ការប្រើប្រាស់ការបញ្ចូល/URL ជាឯកតានៃការវាស់វែងលើគេហទំព័រ**

ជាទូទៅ "URL" (ឬនៅក្នុងលក្ខខណ្ឌរបស់ OONI – input) និង "domain" គឺជាពាក្យដែលអាចផ្លាស់ប្តូរបានដែលត្រូវបានប្រើដើម្បីយោងទៅលើគេហទំព័រណាមួយ។ នៅក្នុងបញ្ជីគេទំព័ររបស់ OONI, URLs ពេញលេញត្រូវបានបញ្ចូលក្នុងកម្មវិធីដែលបានធ្វើតេស្តសម្រាប់ការត្រួតពិនិត្យពិរុទ្ធភាពស្រដៀងនឹង URL ដែលចាប់ផ្តើមដោយ "https" ឬ "http" នៅក្នុងកម្មវិធីរុករក (browser)។ ការត្រួតពិនិត្យពិរុទ្ធភាព អាចពាក់ព័ន្ធនឹងការរារាំងដោយប្រព័ន្ធ DNS, HTTP ឬប្រភេទផ្សេងទៀតនៃការត្រួតពិនិត្យពិរុទ្ធភាព។ ដោយការអាស្រ័យលើវិធីសាស្រ្ត ការបិទខ្ទប់អាចស្ថិតនៅត្រឹមកម្រិត URL ឬកម្រិតដែន។ ទោះជាយ៉ាងណាក៏ដោយនៅពេលវិភាគលទ្ធផលនៅលើកម្មវិធី OONI អ្នកដែលចូលអានត្រូវកត់ចំណាំថាមានភាពខុសប្លែកគ្នានៅក្នុងលេខទាក់ទងនឹងការបញ្ចូល ឬដែនជាក់លាក់។

នៅក្នុងរបាយការណ៍ឆ្នាំ២០២២ ដែនត្រូវបានប្រើជាឯកតានៃការវាស់វែងលើគេហទំព័រ ដើម្បីកាត់បន្ថយការស្ទួនគ្នានៅពេលវាស់វែងចំនួនគេហទំព័រដែលត្រូវបានបិទខ្ទប់។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់របាយការណ៍ឆ្នាំ២០២៣នេះ ការបញ្ចូលត្រូវបានប្រើជំនួសវិញ ព្រោះវាអាចផ្តល់បរិបទកាន់តែទូលាយ ដែលជាហេតុផលនៃការបិទខ្ទប់គេហទំព័រ។ លទ្ធផលរកឃើញក៏នឹងត្រូវបានចាត់ថ្នាក់យ៉ាងត្រឹមត្រូវជាងមុនផងដែរ យោងទៅតាមបញ្ជីគេហទំព័ររបស់ CitizenLab ដែលមានទម្រង់ជា URL។ ដូច្នេះ ដើម្បីយល់កាន់តែច្បាស់អំពីលទ្ធផលរកឃើញនៅលើស្ថានភាពនៃការត្រួតពិនិត្យពិរុទ្ធភាព យើងបានប្រើចំនួនភាគរយនៃការគេហទំព័រដែលត្រូវបានបិទខ្ទប់ ឬទំនងជាត្រូវបានបិទខ្ទប់ ជំនួសឱ្យការរាប់ចំនួនជាក់ស្តែងដោយផ្អែកលើលទ្ធផលតេស្ត OONI ។

- **ភាពខុសគ្នារវាងលេខនិងទិន្នន័យ OONI**

លទ្ធផលនៅក្នុងរបាយការណ៍នេះបានមកពីការវិភាគលំអិតលើទិន្នន័យរបស់OONI ដែលបញ្ជាក់ពីការបិទខ្ទប់ត្រូវយកមកបង្ហាញ និងទិន្នន័យមិនពេញលេញត្រូវបានលុបចោល តាមរយៈវិធីសាស្រ្តអង្កេតយ៉ាងលំអិត និងការផ្ទៀងផ្ទាត់ដោយដៃដោយក្រុមអ្នកស្រាវជ្រាវនៃគម្រោង iMAP ដោយផ្អែកលើបរិបទតាមប្រទេស ឬតាមតំបន់នីមួយៗ។ ខណៈពេលដែលវិធីសាស្រ្តអង្កេតយ៉ាងលំអិត ទាំងនេះនឹងត្រូវបន្ថែមទៅតាមស្នាមម្រាមដៃរបស់ OONI នោះ OONI នឹងដំណើរការវាបាន

សម្រាប់តែការធ្វើតេស្តនាពេលអនាគតប៉ុណ្ណោះ។

លើសពីនេះ ក្រុមអ្នកស្រាវជ្រាវនៃគម្រោង iMAP បានចាត់ថ្នាក់គេហទំព័រដែលត្រូវបានបិទខ្ទប់ ហើយដែលមិនមែនជាផ្នែកនៃបញ្ជីគេហទំព័ររបស់ CitizenLab ប៉ុន្តែត្រូវបានធ្វើតេស្តនៅលើកម្មវិធី OONI តាមរយៈបញ្ជីគេហទំព័រផ្ទាល់ខ្លួន។ ដូច្នេះ តួលេខនៅក្នុងរបាយការណ៍នេះអាចខុសគ្នាទៅនឹងលទ្ធផលនៅលើកម្មវិធី OONI Explorer ។

- **ការធ្វើតេស្តកម្មវិធីផ្ញើសារភ្លាមៗ និងឧបករណ៍បញ្ចៀស**

  កម្មវិធីផ្ញើសារភ្លាមៗ និងឧបករណ៍បញ្ចៀសដែលរួមបញ្ចូលក្នុងរបាយការណ៍នេះ ត្រូវបានដាក់កម្រិតចំពោះកម្មវិធីដែលបានធ្វើតេស្តនៅលើកម្មវិធី OONI ។ ដូច្នេះ វាប្រហែលជាមិនឆ្លុះបញ្ចាំងពីស្ថានភាពនៃការត្រួតពិនិត្យពិរុទ្ធភាពតាមកម្មវិធី ដែលបានប្រើប្រាស់ជាទូទៅនៅក្នុងប្រទេសកម្ពុជានោះទេ។

- **គេហទំព័រដែលអសកម្ម**

  សម្រាប់ប្រទេសកម្ពុជា ជាពិសេសចំពោះគេហទំព័រមួយចំនួនធំដែលត្រូវបានគេរកឃើញត្រូវបានបិទខ្ទប់នោះ គឺអសកម្មតែម្តង។ នៅក្នុងករណីបែបនេះ គេហទំព័រទាំងនោះអាចនៅតែស្ថិតក្នុងបញ្ជីបិទខ្ទប់របស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ទោះបីជាដែនរបស់វាត្រូវគេលែងប្រើ ឬជំនួសថ្មីក៏ដោយ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គេហទំព័រព័ត៌មានអនឡាញ និងគេហទំព័រផ្សេងទៀតត្រូវបានគេរកឃើញថាត្រូវបានបិទចោលជាប្រចាំនៅក្នុងប្រទេសកម្ពុជា។ លទ្ធផលរកឃើញរបស់យើងបង្ហាញថាគេហទំព័រសរុបចំនួន ៣៦ ក្នុងចំណោម ២,២០២ ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ត្រូវបានបិទខ្ទប់ ជាពិសេសគេហទំព័រដែលផ្សព្វផ្សាយព័ត៌មានដែលគេយល់ថាជាការគំរាមកំហែងដល់រដ្ឋាភិបាលកំពុងកាន់អំណាច។ ដូច្នេះគេអាចសន្និដ្ឋានបានថា សេរីភាពសារព័ត៌មាន និងសេរីភាពអ៊ីនធឺណិតនៅប្រទេសកម្ពុជា កំពុងស្ថិតក្រោមការគំរាមកំហែងជាបន្តបន្ទាប់។ នៅឆ្នាំ ២០២២ និងឆ្នាំ២០២៣ ប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេស "មិនសេរី" ហើយប្រជាជនមានការភ័យខ្លាចក្នុងការបញ្ចេញមតិ ឬមិនហ៊ានបញ្ចេញមតិយោបល់របស់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសក្រុមអ្នកដែលហ៊ានរិះគន់រដ្ឋាភិបាល។

យោងតាមលទ្ធផលរកឃើញ ចំនួន ៣៥.១% នៃគេហទំព័រដែលបានបិទខ្ទប់ គឺជាគេហទំព័រផ្សព្វផ្សាយព័ត៌មាន។ មានករណីនៃការត្រួតពិនិត្យពិរុទ្ធភាព និងករណីនៃការចាំឃ្លាំមើលតាមអ៊ីនធឺណិតជាច្រើន ត្រូវបានរាយការណ៍នៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។[19] លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ និងទើបបង្កើតថ្មីៗដើម្បីបង្កើនការជ្រៀតជ្រែករបស់ខ្លួន។ ការដាក់កំហិតលើវិធានការផ្លូវច្បាប់ និងមិនស្របច្បាប់ដោយរាជរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងក្រុម ឬបុគ្គលជាគោលដៅ បានរឹតបន្តឹងជាអវិជ្ជមានដល់ការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ីនធឺណិត។

គេហទំព័រទាំងនេះរួមមានគេហទំព័រសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ដូច្នេះហើយវាជាការបង្កើនក្តីព្រួយបារម្ភអំពីសេរីភាពសារព័ត៌មាន សេរីភាពអ៊ីនធឺណិត និងការរឹតត្បិតនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែទិន្នន័យបច្ចុប្បន្នពីប្រទេសកម្ពុជាមិនបានបង្ហាញគេហទំព័រដែលត្រូវបានបិទខ្ទប់ ទើបការវាស់វែងបន្ថែមទៀតអាចនឹងត្រូវការជាចាំបាច់ក្នុងការរាយការណ៍នៅជុំបន្ទាប់ ដើម្បីធ្វើការសន្និដ្ឋានឱ្យបានច្រើនជាអាទិ៍ថែមទៀត។

ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងរយៈពេលធ្វើរបាយការណ៍នេះ នៅចន្លោះខែមករា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២២ និងខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣ បង្ហាញថាចំនួននៃការបិទខ្ទប់មានការថយចុះតិចតួច ពីចំនួន ៤៣ គេហទំព័រ មកនៅត្រឹមចំនួន ៣៦ គេហទំព័រ បើទោះបីជាមិនបានបង្ហាញដោយផ្ទាល់នូវការកាត់បន្ថយការត្រួតពិនិត្យពិរុទ្ធភាព ដោយសារគេហទំព័រដែលបានធ្វើតេស្តនោះមានលក្ខណៈខុសៗគ្នា។ គេហទំព័រនានាទំនងជាត្រូវបានរារាំងដោយប្រព័ន្ធ DNS និងបញ្ជាក់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (Viettel, Wicam, CamSIM, Ezecom, Private Company (iSEEK))។ គេហទំព័រទាំង ៣៦ ដែលបានបិទខ្ទប់ ត្រូវបានត្រួតពិនិត្យពិរុទ្ធភាពដោយប្រព័ន្ធ DNS ដែលភាគច្រើនធ្វើឡើងដោយក្រុមហ៊ុន VIETTEL (CAMBODIA) PTE., LTD. (AS38623), S.I Group (AS38623) និងក្រុមហ៊ុន CAMGSM Company Ltd (AS17976) ក្នុងឆ្នាំ២០២២។ ដូច្នេះហើយ យើងចាត់ទុកសេរីភាពសារព័ត៌មាន និងសេរីភាពអ៊ីនធឺណិតនៅប្រទេសកម្ពុជាបច្ចុប្បន្នកំពុងស្ថិតក្រោមការគំរាមកំហែងជាបន្តបន្ទាប់។

[19] The letter from Ministry of Information issued on 13th February 2023 ordered to shutdown VOD.

ផ្អែកលើការវិភាគ និងលទ្ធផលរកឃើញក្នុងរបាយការណ៍នេះ យើងសូមបញ្ជាក់ជាថ្មីម្តងទៀតនូវអនុសាសន៍ដែលធ្វើឡើងដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។ OHCHR សូមផ្តល់ជាអនុសាសន៍ដល់រដ្ឋជាភាគី (ប្រទេសកម្ពុជា) ត្រូវពិនិត្យ និងកែសម្រួលច្បាប់បច្ចុប្បន្ន និងច្បាប់ទាំងឡាយណាដែលមិនទាន់សម្រេចនៅឡើយ រួមទាំងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ និងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រដែលបែកធ្លាយ និងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត។ យើងក៏សូមផ្តល់អនុសាសន៍ផងដែរថា សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលនឹងត្រូវអនុម័តនោះ ត្រូវប្រាដកថាមិនគួរប្រើប្រាស់បច្ចេកសព្ទមិនច្បាស់លាស់ និងការដាក់កម្រិតជ្រុលពេកនោះទេ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សូមផ្តល់អនុសាសន៍បន្ថែមថា រដ្ឋជាសមាជិកត្រូវធានាចំពោះការបង្កើត និងការអនុវត្តច្បាប់របស់ខ្លួន រួមទាំងអនុក្រឹត្យរបស់រដ្ឋមន្ត្រី ការរឹតបន្តឹងលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការបង្កើតសមាគម ដោយអនុលោមតាមលក្ខខណ្ឌតម្រូវយ៉ាងតឹងរឹងត្រង់មាត្រា ១៩ (៣) និងមាត្រា ២២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីសិទ្ធិមនុស្ស។

សរុបមក រដ្ឋាភិបាលគួរតែពិនិត្យ និងពិចារណាឡើងវិញលើការលើកទឹកចិត្តដល់គេហទំព័រទាំងឡាយណាដែលត្រូវបានបិទខ្ទប់ ដែលជាការអនុវត្តសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ីនធឺណិត។

## ការចុះឈ្មោះលើប្រព័ន្ធឈ្មោះដែន (.kh)

នាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា តម្រូវឱ្យក្រុមហ៊ុនចុះឈ្មោះប្រព័ន្ធឈ្មោះដែនក្នុងតំបន់ (.kh) ចំពោះគេហទំព័រ និងអ៊ីមែលរបស់ពួកគេក្នុងខែមករា ឆ្នាំ២០២៣ ទោះបីជាថ្ងៃផុតកំណត់នេះហាក់ដូចជាមិនបានអនុវត្តយ៉ាងតឹងតែងក៏ដោយ។[20] ជាក់ស្តែង មានដែនចំនួន ៣,២៥៥ ដែលបានចុះឈ្មោះរួចហើយ។[21] លើសពីនេះ វាមិនមែនជាការបង្ខិតបង្ខំឱ្យអង្គការសង្គមស៊ីវិលថាត្រូវតែចុះឈ្មោះដែន (.kh) របស់ពួកគេទេ។

យើងមានការព្រួយបារម្ភថាសេចក្តីព្រាងច្បាប់/បទប្បញ្ញត្តិថ្មីនេះ នឹងក្លាយជាការដាក់កំហិតសម្រាប់អង្គការសង្គមស៊ីវិលក្នុងស្រុក ក្រុមហ៊ុន និងសូម្បីតែបុគ្គលម្នាក់ៗក្នុងការចុះឈ្មោះដែន (.kh)។ ច្បាប់នេះរួមចំណែកដល់ការគ្រប់គ្រងកាន់តែខ្លាំងក្លារបស់រដ្ឋាភិបាលលើសិទ្ធិប្រើប្រាស់អ៊ីនធឺណិត និងអាចដាក់កម្រិតសេរីភាពទទួលព័ត៌មាន។ ដូច្នេះ យើងស្នើឱ្យរដ្ឋាភិបាលដកបទប្បញ្ញត្តិបែបនេះចេញ កុំឱ្យឈានដល់ការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិតាមអ៊ីនធឺណិត។

រដ្ឋាភិបាលគួរតែអនុវត្តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងអនុវត្តតាមច្បាប់ និងគោលការណ៍នៃការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមអ្នកផ្តល់សេវាទាក់ទងនឹងផលិតផល និងសេវាកម្មឌីជីថល។ បើមើលពីទស្សនៈយុត្តិធម៌សង្គម និងទស្សនៈប្រសិទ្ធភាពសេដ្ឋកិច្ច បញ្ហាសិទ្ធិឌីជីថលមានផលប៉ះពាល់ជាច្រើន។ ជាទស្សនៈយុត្តិធម៌សង្គម មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសិទ្ធិសេរីភាពសង្គម នយោបាយ និងសេដ្ឋកិច្ច ដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ឆ្នាំ ១៩៦៦។ ជាទស្សនៈប្រសិទ្ធភាពសេដ្ឋកិច្ច វាបង្ហាញឱ្យឃើញពីការដាក់កម្រិតលើសិទ្ធិឌីជីថលដើម្បីបង្កឱ្យមាន "ផលប៉ះពាល់សក្តានុពល" លើការប្រកួតប្រជែងលើទស្សនៈពីរសងខាងចំពោះបញ្ហាតែមួយ។ នៅជ្រុងម្ខាងនៃបញ្ហា គឺការរារាំងគោលការណ៍នៃការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមអ្នកផ្តល់សេវាទាក់ទងនឹង

[20] Ogden, J. (2023, January 29). *Register .kh Domain Names in Cambodia - Cambodia Begins at 40*. Cambodia Begins at 40. https://www.cambodiabeginsat40.com/?p=41005

[21] *Internet Subscriptions | Telecommunication Regulator of Cambodia*. (n.d.). Internet Subscriptions | Telecommunication Regulator of Cambodia. https://trc.gov.kh/en/internet-subscriptions/

ផលិតផល និងសេវាកម្មឌីជីថលដែលបានផ្តល់ឱ្យ ប្រសិនបើមានការសម្រេចចិត្តបិទខ្ទប់ ឬរឹតត្បិតចំពោះគេហទំព័រធុរកិច្ចដែលភាគច្រើនគឺជាគេហទំព័រវែបពាណិជ្ជកម្ម ត្រូវបានធ្វើឡើងដោយគ្មាននីតិវិធីអាជ្ញាកណ្តាល។

នៅជ្រុងម្ខាងទៀតនៃបញ្ហា គឺសហគ្រាសធុនតូច និងមធ្យម (SMEs) ប្រហែលជាមិនមានសមត្ថភាព និងចំណេះដឹងគ្រប់គ្រាន់ដើម្បីធានាការអនុវត្តពាណិជ្ជកម្មរបស់ពួកគេ ដោយគ្មានហានិភ័យខ្ពស់ដោយសារការរឹតត្បិត ការបិទខ្ទប់ ឬការត្រួតពិនិត្យពិរុទ្ធភាពនោះទេ។ សម្រាប់ហេតុផលនេះ មជ្ឈត្តកម្មយុត្តិធម៌ ឬនីតិវិធីតុលាការ គឺតម្រូវឱ្យមានជាចាំបាច់សម្រាប់ការផ្លាស់ប្តូរទម្រង់ឌីជីថលបែបនេះ។

## រួមចំណែកក្នុងការសិក្សា

ប្រសិនបើអ្នកចង់រួមចំណែកក្នុងការវាស់វែងលើការតាមដានការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត (OONI) មានវិធីជាច្រើនដែលអ្នកអាចចូលរួមបាន ដូចជា៖

- ការធ្វើតេស្ត៖ អ្នកអាចធ្វើតេស្តនៅលើវេទិកាផ្សេងៗ various platforms ទាំងនៅលើទូរសព្ទដៃ (iOS និង Android) និង Desktop រួមទាំងនៅលើ CLI នៅលើវេទិកា Linux។ ដែនដែលអ្នកធ្វើតេស្តអាចត្រូវបានជ្រើសរើសដោយចៃដន្យពីបញ្ជីគេហទំព័រ CitizenlabTestLists ឬបញ្ជីគេហទំព័រផ្ទាល់ខ្លួនដែលជាក់លាក់ចំពោះតម្រូវការរបស់អ្នក។
- ចូលរួមចំណែកក្នុងបញ្ជីគេហទំព័រ៖ អ្នកអាចរួមចំណែកក្នុងបញ្ជីគេហទំព័រនៅលើ GitHub ឬនៅលើ OONI។
- ការបកប្រែ៖ បកប្រែកម្មវិធី OONI Probe ទៅជាភាសាជាតិរបស់អ្នកនៅទីនេះ here។
- ចូលរួមជាមួយសហគមន៍៖ ចូលរួមក្នុងការពិភាក្សាសហគមន៍នៅលើ OONI’sSlackchannel។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដល់ដៃគូក្នុងស្រុក សកម្មជន អ្នកសិក្សា អ្នកស្រាវជ្រាវ និងអ្នកប្រើប្រាស់អនាមិកក្នុងប្រទេសកម្ពុជា សម្រាប់ជំនួយឧបត្ថម្ភរបស់ពួកគេក្នុងការដំណើរការកម្មវិធី OONI Probe ។

# ឧបសម្ព័ន្ធ ៖ បញ្ជីគេហទំព័រដែលបានបញ្ជាក់ថាបានបិទខ្ទប់

| ល.រ | គេហទំព័រ / URL | ប្រភេទ | ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតដែលជាអ្នកបិទខ្ទប់ | វិធីបិទខ្ទប់ | តំណភ្ជាប់k | ប្រទេស | សម្គាល់ |
|---|---|---|---|---|---|---|---|
| 1 | https://securevpn.im/ | ANON | Viettel (Metfone) | DNS | Link | សកល | សកម្ម |
| 2 | https://www.iconnecthere.com/ | COMT | Viettel (Metfone) | DNS | Link | សកល | សកម្ម |
| 3 | https://www.epa.gov/ | GOVT | Viettel (Metfone),CamGSM, Ezecom,Wicam | DNS | Link | សកល | សកម្ម |
| 4 | http://www.qhtyzx.com/ | NEWS | Viettel (Metfone) | DNS | Link | ខ្មែរ | សកម្ម |
| 5 | https://vodenglish.news/ | NEWS | Ezecom | DNS | Link | ខ្មែរ | សកម្ម |
| 6 | https://vodkhmer.news/ | NEWS | Ezecom | DNS | Link | ខ្មែរ | សកម្ម |
| 7 | https://www.rfa.org/ | NEWS | SINET, WICAM | DNS | Link | ខ្មែរ | សកម្ម |
| 8 | https://english.cambodiadaily.com | NEWS | SINET | DNS | Link | ខ្មែរ | សកម្ម |
| 9 | https://vodhotnews.com | NEWS | WiCAM Corporation Ltd., Viettel (Metfone), EZECOM limited, KingCorp Inc, COGETEL Co., Ltd, S.I Group, Smart Axiata, Co., Ltd., CAMGSM Company Ltd | DNS | Link | ខ្មែរ | សកម្ម |
| 10 | https://dailystormer.name/ | POLR | Viettel (Metfone) | DNS | Link | ខ្មែរ | សកម្ម |
| 11 | https://occupystreams.org/ | POLR | Ezecom,Wicam | DNS | Link | ខ្មែរ | សកម្ម |
| 12 | http://www.teenhealthfx.com/ | XED | Viettel (Metfone) | DNS | Link | សកល | សកម្ម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 13 | https://www.cipl-organization.org | CULTR | Viettel (Metfone) | DNS | ~~Link~~ | ខ្មែរ | ដែនដាក់លក់ |
| 14 | http://www.adhoc-cambodia.org/ | HUMR | Viettel (Metfone) | DNS | ~~Link~~ | សកល | ដែនដាក់លក់ |
| 15 | http://stubes.info/onlain/italbGdoRW1hS2JrOGc | NEWS | Viettel (Metfone) | DNS | ~~Link~~ | សកល | ដែនដាក់លក់ |
| 16 | http://www.kirivong.com/ | NEWS | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | សកល | ដែនដាក់លក់ |
| 17 | http://www.ksn-news.com/ | NEWS | Viettel (Metfone | DNS | ~~Link~~ | សកល | ដែនដាក់លក់ |
| 18 | https://www.monorom.info/ | NEWS | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | ខ្មែរ | ដែនដាក់លក់ |
| 19 | http://www.healthcambodia.org/ | PUBH | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | សកល | ដែនដាក់លក់ |
| 20 | https://site.voicepulse.com/ | COMT | Viettel (Metfone),private companies (iSeeK), Wicam | DNS | ~~Link~~ | សកល | អសកម្ម |
| 21 | https://cambodian.dating/ | DATE | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 22 | https://bitcoin-mix.org/ | ECON | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 23 | https://sci-hub.se/ | FILE | Viettel (Metfone) | DNS | ~~Link~~ | ខ្មែរ | អសកម្ម |
| 24 | https://www.libgen.tw/ | FILE | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 25 | https://scontent-frt3-2.cdninstagr | GRP | Viettel (Metfone),private companies (iSeeK), CamGSM | DNS | ~~Link~~ | សកល | អសកម្ម |
| | am.com/favicon.ico | | | | | | |
| 26 | http://www.nazi-lauck-nsdapao.com | HATE | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 27 | http://ocsp.int-x3.letsencrypt.org | HOST | Viettel(Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 28 | http://www.ycc.org.kh/ | HUMR | Viettel (Metfone),private companies (iSeeK), CamGSM | DNS | ~~Link~~ | ខ្មែរ | អសកម្ម |
| 29 | http://hdhdhdgd.com | MISC | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 30 | https://secure.flickr.com/ | MMED | Viettel (Metfone),private companies (iSeeK), Wicam | DNS | ~~Link~~ | សកល | អសកម្ម |
| 31 | http://www.repubblica.com/ | NEWS | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | ខ្មែរ | អសកម្ម |
| 32 | http://www.ruf-ch.org/ | NEWS | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | សកល | អសកម្ម |
| 33 | https://khmer.cambodiadaily.com | NEWS | Viettel (Metfone),private companies (iSeeK) | DNS | ~~Link~~ | ខ្មែរ | អសកម្ម |
| 34 | http://www.islamdoor.com/ | REL | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 35 | http://khmer.cambodiadaily.com/ | NEWS | Viettel (Metfone), private companies (iSeeK), SINET, | DNS | ~~Link~~ | សកល | អសកម្ម |
| 36 | http://www.cannabis.info/ | MSC | Viettel (Metfone) | DNS | ~~Link~~ | សកល | អសកម្ម |
| 37 | http://www.hrcr.org/ | HUMR | Viettel (Metfone) | DNS | ~~Link~~ | ខ្មែរ | អសកម្ម |

## ឧបសម្ព័ន្ធ II៖តារាងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត

| ល.រ | ASNs | ឈ្មោះ ASN | ប្រទេសចុះឈ្មោះ ASN |
|---|---|---|---|
| 1 | AS23673<br>AS24325 | Cogetel Online | KH |
| 2 | AS24478 | AngkorNet | KH |
| 3 | AS38901 | EZECOM | KH |
| 4 | AS38623 | Viettel (Metfone) | KH |
| 5 | AS38893 | Clicknet | KH |
| 6 | AS17976 | TeleSURF / Mobitel | KH |
| 7 | AS24492 | WiCam | KH |
| 8 | AS17726 | CamNet | KH |
| 9 | AS45348 | Chuan Wei | KH |
| 10 | AS18014<br>AS24441 | City Link | KH |
| 11 | AS38209 | Camintel | KH |
| 12 | AS131186<br>AS131203 | MekongNet | KH |
| 13 | AS45498 | Smart Mobile | KH |
| 14 | AS38235 | MekongNet IXP | KH |
| 15 | AS24567 | WirelessIP | KH |
| 16 | AS45339 | BeyondTel | KH |
| 17 | AS7712 | CIDC IT | KH |
| 18 | AS17981 | Cambo Technology | KH |
| 19 | AS45429 | DTV Star | KH |
| 20 | AS38600<br>AS45281 | Hello | KH |
| 21 | AS9902<br>AS23868 | NeocomISP | KH |
| 22 | AS38286 | PPCTV | KH |
| 23 | AS45124 | Finder IXP | KH |
| 24 | AS38723 | Star-Cell | KH |
| 25 | AS45465 | Flash Tech | KH |
| 26 | AS131178 | Opennet | KH |
| 27 | AS131207 | S.I Net | KH |
| 28 | AS38579 | CB | KH |

# ឧបសម្ព័ន្ធ III៖ សន្ទានុក្រម

| | |
|---|---|
| DNS | DNS តំណាងឱ្យពាក្យថា "ប្រព័ន្ធឈ្មោះដែន" ហើយវាមានមុខងារកំណត់ឈ្មោះដែនទៅកាន់អាសយដ្ឋាន IP ។<br><br>ដែន គឺជាឈ្មោះដែលជាទូទៅត្រូវបានកំណត់គុណលក្ខណៈគេហទំព័រនៅពេលដែលគេហទំព័រនោះត្រូវបានបង្កើតឡើង។ ដែន អនុញ្ញាតឱ្យគេហទំព័រអាចចូលប្រើបាន និងងាយចងចាំបាន។ ឧ. twitter.com គឺជាដែននៃគេហទំព័ររបស់ក្រុមហ៊ុន Twitter ។<br><br>ទោះយ៉ាងណាក៏ដោយ កុំព្យូទ័រមិនអាចតភ្ជាប់ទៅសេវាអ៊ីនធឺណិតតាមរយៈឈ្មោះដែនបានទេ។ គេអាចតភ្ជាប់តាមរយៈអាសយដ្ឋាន IP៖ អាសយដ្ឋានឌីជីថលនៃសេវាកម្មនីមួយៗនៅលើប្រព័ន្ធអ៊ីនធឺណិត។ ស្រដៀងគ្នានេះដែរ នៅក្នុងពិភពរូបវន្ត អ្នកនឹងចាំបាច់ត្រូវការអាសយដ្ឋានលំនៅឋានមួយ (ជាជាងឈ្មោះលំនៅឋានខ្លួនឯង) ដើម្បីចូលទៅមើលវាបាន។<br><br>ប្រព័ន្ធឈ្មោះដែន (DNS) ទទួលខុសត្រូវក្នុងការបំប្លែងឈ្មោះដែនដែលអាចអានបានដោយមនុស្ស (ដូចជា ooni.org) ទៅជាអាសយដ្ឋាន IP ជាលេខរបស់វា (ក្នុងករណីនេះគឺលេខ៖ 104.198.14.52) ដូច្នេះអាចអនុញ្ញាតឱ្យកុំព្យូទ័ររបស់អ្នកចូលទៅកាន់គេហទំព័រដែលចង់ចូលទៅមើល។ |
| HTTP | Hypertext Transfer Protocol (HTTP) គឺជាពិធីសារមូលដ្ឋានដែលប្រើដោយ World Wide Web ដើម្បីផ្ទេរ ឬផ្លាស់ប្តូរទិន្នន័យឆ្លងកាត់ប្រព័ន្ធអ៊ីនធឺណិត។<br><br>ពិធីសារ HTTP អនុញ្ញាតឱ្យមានទំនាក់ទំនងរវាងម៉ាស៊ីនសឺវើអតិថិជន និងម៉ាស៊ីនសឺវើមេ។ វាមានមុខងារដោះស្រាយសំណើរបស់អតិថិជនដើម្បីភ្ជាប់ទៅម៉ាស៊ីនសឺវើមេ និងការឆ្លើយតបរបស់ម៉ាស៊ីនសឺវើមេចំពោះសំណើរបស់អតិថិជនវិញ។<br><br>គេហទំព័រទាំងអស់រួមបញ្ចូលបុព្វបទ HTTP ឬ HTTPS (ដូចជា http://example.com/) ដូច្នេះទើបកុំព្យូទ័ររបស់អ្នក (អតិថិជន) អាចស្នើសុំ និងទទួលមាតិកានៃគេហទំព័របាន (បង្ហោះនៅលើម៉ាស៊ីនសឺវើមេ)។<br><br>ការបញ្ជូនទិន្នន័យតាមពិធីសារ HTTP មិនត្រូវបានធ្វើកូដនីយកម្មទេ។ |
| Heuristics | Heuristics ទទួលបាននូវការបិទខ្ទប់ដែលបានបញ្ជាក់បន្ថែមក្រៅពីអ្វីដែលត្រូវបានរកឃើញដោយផ្អែកលើ OONI ដែលបិទខ្ទប់ស្នាមម្រាមដៃ។ ការពន្យល់លម្អិតបន្ថែមទៀត អាចស្វែងរកនៅទីនេះ៖ here។ |

| | |
|---|---|
| ISP | ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) គឺជាអង្គភាពដែលផ្តល់សេវាកម្មសម្រាប់ការចូលប្រើ និងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។<br>ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) អាចជាកម្មសិទ្ធិរបស់រដ្ឋ ជាលក្ខណៈពាណិជ្ជកម្ម ជាកម្មសិទ្ធិសហគមន៍ មិនសំដៅរកប្រាក់ចំណេញ ឬជាកម្មសិទ្ធិឯកជន។<br>Vodafone, AT&T, Airtel, និង MTN គឺជាឧទាហរណ៍នៃ ISPs ។ |
| Middle boxes | ប្រអប់កណ្តាល គឺជាឧបករណ៍បណ្តាញកុំព្យូទ័រដែលបំប្លែង ត្រួតពិនិត្យ ត្រងច្រោះ ឬរៀបចំចរាចរសម្រាប់គោលបំណងផ្សេងក្រៅពីការបញ្ជូនបន្តនូវសំណុំកញ្ចប់ព័ត៌មាន។<br>ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) ជាច្រើននៅជុំវិញពិភពលោកកំពុងប្រើប្រាស់ប្រអប់កណ្តាលដើម្បីកែលម្អដំណើរការបណ្តាញ ដើម្បីផ្តល់ឱ្យអ្នកប្រើប្រាស់នូវការចូលទៅកាន់គេហទំព័របានកាន់តែលឿន និងសម្រាប់គោលបំណងបណ្តាញផ្សេងៗទៀត។<br>Middleboxes ពេលខ្លះត្រូវបានប្រើដើម្បីអនុវត្តការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិត និង/ឬការចាំឃ្លាំមើល។<br>កម្មវិធី OONI Probe រួមបញ្ចូលការធ្វើតេស្តចំនួនពីរដែលត្រូវបានរចនាឡើងដើម្បីវាស់វែងបណ្តាញក្នុងគោលដៅកំណត់អត្តសញ្ញាណវត្តមានរបស់ប្រអប់កណ្តាល។ |
| TCP | ពិធីសារត្រួតពិនិត្យការបញ្ជូន (TCP) គឺជាពិធីសារដ៏សំខាន់មួយក្នុងចំណោមពិធីសារដទៃទៀតនៅលើប្រព័ន្ធអ៊ីនធឺណិត។<br>ដើម្បីភ្ជាប់ទៅគេហទំព័របាន កុំព្យូទ័ររបស់អ្នកចាំបាច់ត្រូវបង្កើតការតភ្ជាប់ TCP ទៅកាន់អាសយដ្ឋាននៃគេហទំព័រនោះតែម្តង។<br>TCP ដំណើរការនៅលើកំពូលនៃ Internet Protocol (IP) ដែលកំណត់និយមន័យពីរបៀបដោះស្រាយចំពោះកុំព្យូទ័រនៅលើអ៊ីនធឺណិត។ នៅពេលនិយាយទៅកាន់ម៉ាស៊ីនលើពិធីសារ TCP, អ្នកចាំបាច់ត្រូវប្រើ IP និងច្រកគូ ដែលមើលទៅដូចលេខនេះ៖ 10.20.1.1:8080។<br>ភាពខុសគ្នាសំខាន់រវាង TCP និង (ពិធីសារដ៏ពេញនិយមមួយទៀតហៅថា UDP) គឺថា TCP មានសញ្ញាណនៃ "ការតភ្ជាប់" ដែលធ្វើឱ្យវាក្លាយជាពិធីសារដឹកជញ្ជូនដែលអាចទុកចិត្តបាន។ |

| | |
|---|---|
| TLS | Transport Layer Security (TLS) – សំដៅផងដែរថាជា SSL – គឺជាពិធីសារកូដនីយកម្មដែលអនុញ្ញាតឱ្យអ្នកអាចរក្សាការតភ្ជាប់ដែលមានសុវត្ថិភាព និងនិងដោយកូដនីយកម្មរវាងកុំព្យូទ័ររបស់អ្នក និងសេវាកម្មអ៊ីនធឺណិត។<br><br>នៅពេលណាដែលអ្នកភ្ជាប់ទៅកាន់គេហទំព័រតាមរយៈ TLS នោះអាសយដ្ឋានគេហទំព័រនឹងចាប់ផ្តើមជាមួយតួអក្សរ HTTPS (ដូចជា https://www.facebook.com/) ជំនួសឱ្យតួអក្សរ HTTP ។ |

សទ្ទានុក្រមដ៏ទូលំទូលាយដែលទាក់ទងនឹងកម្មវិធី OONI អាចស្វែងរកនៅទីនេះ: https://ooni.org/support/glossary/

# ឧបសម្ព័ន្ធ IV: វិធីសាស្ត្រ

## ទិន្នន័យ

ទិន្នន័យដែលបានគណនាដោយផ្អែកលើ heuristics សម្រាប់របាយការណ៍នេះអាចទាញយកបាននៅទីនេះ៖ https://github.com/Sinar/imap-data, ចំណែកទិន្នន័យសរុបអាចទាញយកបានពី OONI Explorer

## ការគ្របដណ្តប់នៃរបាយការណ៍

របាយការណ៍នៃគម្រោង iMAP ស្តីពីប្រទេសដែលត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណេត គឺបានគ្របដណ្តប់លើលទ្ធផលរកឃើញនៃការវាស់វែងបណ្តាញដែលប្រមូលបានតាមរយៈកម្មវិធី OONIProbeApp ដែលវាស់វែងការបិទខ្ទប់គេហទំព័រ កម្មវិធីផ្ញើសារភ្លាមៗ ឧបករណ៍បញ្ចៀស និងការរំខានបណ្តាញ។ លទ្ធផលរកឃើញនេះគូសបញ្ជាក់ពីគេហទំព័រ កម្មវិធីផ្ញើសារភ្លាមៗ និងឧបករណ៍បញ្ចៀសទាំងឡាយដែលត្រូវបានបញ្ជាក់ថាត្រូវបានបិទខ្ទប់ ក៏ដូចជា ASNs ជាមួយនឹងការត្រួតពិនិត្យពិរុទ្ធភាពដែលបានរកឃើញ និងវិធីសាស្ត្រនៃការជ្រៀតជ្រែកបណ្តាញដែលបានអនុវត្ត។ របាយការណ៍នេះក៏ផ្តល់នូវបរិបទជាសាវតានៅលើទិដ្ឋភាពបណ្តាញរួមជាមួយនឹងស្ថានភាពចុងក្រោយបំផុតនៃផ្លូវច្បាប់ សង្គម និងនយោបាយ និងព្រឹត្តិការណ៍ដែលអាចប៉ះពាល់ដល់ការអនុវត្តការត្រួតពិនិត្យពិរុទ្ធភាពតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

នៅក្នុងលក្ខខណ្ឌនៃពេលវាកំណត់ របាយការណ៍របស់គម្រោង iMAP នេះគ្របដណ្តប់លើការវាស់វែងដែលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។ ប្រទេសដែលគ្របដណ្តប់ក្នុងជុំនៃសេចក្តីរាយការណ៍នេះគឺប្រទេសកម្ពុជា ហុងកុង ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ វៀតណាម ទីម័រខាងកើត និងឥណ្ឌា។

## តើការវាស់វែងបណ្តាញត្រូវបានប្រមូលផ្តុំដោយរបៀបណា?

ការវាស់វែងបណ្តាញត្រូវបានប្រមូលផ្តុំតាមរយៈការប្រើប្រាស់ OONIProbeapp ដែលជាឧបករណ៍កម្មវិធីទន់ឥតគិតថ្លៃដែលបង្កើតឡើងដោយគម្រោងOpen Observatory of Network Interference(OONI)។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដំណើរការការធ្វើតេស្ត OONI Probe test សូមចូលទៅកាន់គេហទំព័រhttps://ooni.org/nettest/។

ក្រុមអ្នកស្រាវជ្រាវតាមប្រទេសនីមួយៗនៃគម្រោង iMAP និងក្រុមអ្នកស្ម័គ្រចិត្តអនាមិក បានដំណើរការកម្មវិធី OONI Probe ដើម្បីពិនិត្យមើលលទ្ធភាពប្រើប្រាស់គេហទំព័រដែលរួមបញ្ចូលក្នុងបញ្ជី Citizen Lab test lists។ ក្រុមអ្នកស្រាវជ្រាវតាមប្រទេសនីមួយៗនៃគម្រោង iMAP បានពិនិត្យយ៉ាងសកម្មនូវបញ្ជីគេហទំព័រជាក់លាក់របស់ប្រទេសនីមួយៗ ដើម្បីធានាថាគេហទំព័រអាប់ដេតត្រូវបានរួមបញ្ចូល ហើយគេហទំព័រដែលទាក់ទងនឹងបរិបទត្រូវបានចាត់ថ្នាក់យ៉ាងត្រឹមត្រូវ នៅក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងជាមួយដៃគូបណ្តាញសិទ្ធិឌីជីថល។ យើងទទួលយកការអនុវត្តតាមវិធីសាស្ត្រដែលធ្វើឡើងដោយ approach taken by Netalitica ក្នុងការពិនិត្យមើលបញ្ជីគេហទំព័រជាក់លាក់តាមប្រទេសនីមួយៗ។

វាជាការសំខាន់ក្នុងការកត់សម្គាល់ថាលទ្ធផលរកឃើញ អាចអនុវត្តបានចំពោះតែគេហទំព័រដែលត្រូវបានពិនិត្យ ហើយមិនឆ្លុះបញ្ចាំងពេញលេញនូវគ្រប់ករណីនៃការត្រួតពិនិត្យពិរុទ្ធភាពដែលអាចកើតមានក្នុងអំឡុងពេលធ្វើតេស្តនោះទេ។

## តើការវាស់វែងបណ្តាញត្រូវបានវិភាគយ៉ាងដូចម្តេច?

OONI ដំណើរការនូវប្រភេទទិន្នន័យតាមរយៈលំហូរទិន្នន័យ data pipeline ដូចខាងក្រោម៖

### លេខកូដប្រទេស

តាមលំនាំដើម OONI ប្រមូលលេខកូដដែលត្រូវគ្នានឹងប្រទេសដែលអ្នកប្រើប្រាស់កំពុងដំណើរការធ្វើតេស្តកម្មវិធី OONI Probe។ វាដំណើរការដូច្នេះបានដោយការស្វែងរកស្វ័យប្រវត្តិដោយផ្អែកលើអាសយដ្ឋាន IP របស់អ្នកប្រើតាមរយៈ ASN database and និង Max MindGeo IP database។

### លេខប្រព័ន្ធស្វយ័តភាព ( ASN )

តាមលំនាំដើម OONI ប្រមូលលេខប្រព័ន្ធស្វយ័តភាព (ASN) នៃបណ្តាញដែលប្រើប្រាស់ ដើម្បីដំណើរការកម្មវិធី OONI Probe ដូច្នេះហើយដើម្បីបង្ហាញអ្នកផ្តល់បណ្តាញរបស់អ្នកប្រើប្រាស់។

### កាលបរិច្ឆេទ និងពេលវេលានៃការវាស់វែង

តាមលំនាំដើម OONI ប្រមូលពេលវេលា និងកាលបរិច្ឆេទនៅពេលដែលការធ្វើតេស្តត្រូវបានដំណើរការ ដើម្បីវាយតម្លៃនៅពេលដែលមានការជ្រៀតជ្រែកបណ្តាញកើតឡើង និងអនុញ្ញាតឱ្យមានការប្រៀបធៀបតាមពេលវេលា។ ទិន្នន័យពេលវេលា និងកាលបរិច្ឆេទប្រើប្រាស់ UTC ជាតំបន់ពេលវេលាស្តង់ដារ។ លើសពីនេះ បញ្ជីដែលបានបង្កើតនៅលើ OONI MAT មិនរាប់បញ្ចូលការវាស់វែងនៅថ្ងៃចុងក្រោយតាមលំនាំដើមទេ។

### ប្រភេទ

គេហទំព័រចំនួន ៣២ ប្រភេទ គឺផ្អែកលើបញ្ជីគេហទំព័រ៖ https://github.com/citizenlab/test-lists។ ដោយសារតែគេហទំព័រទាំងអស់ដែលបានធ្វើតេស្តនៅលើ OONI មិនមែនសុទ្ធតែមាននៅក្នុងបញ្ជីគេហទំព័រទាំងនេះ ទើបគេហទំព័រមួយចំនួននឹងមិនត្រូវបានចាត់ថ្នាក់តាមប្រភេទនោះទេ។

| ល.រ | បរិយាយប្រភេទ | កូដ | បរិយាយ |
|---|---|---|---|
| ១ | គ្រឿងស្រវឹង និងគ្រឿងញៀន | ALDR | គេហទំព័រដែលផ្តោតលើការប្រើប្រាស់ គ្រឿងបរិក្ខារ និងការលក់គ្រឿងញៀន និងគ្រឿងស្រវឹង ដោយមិនគិតពីភាពស្របច្បាប់ក្នុងតំបន់។ |
| ២ | សាសនា | REL | គេហទំព័រផ្តោតលើការពិភាក្សាអំពីបញ្ហាសាសនា ទាំងការគាំទ្រ និងការរិះគន់ ក៏ដូចជាការពិភាក្សាអំពីក្រុមសាសនាភាគតិច។ |
| ៣ | ភាពអាសអាភាស | PORN | ភាពអាសអាភាសទាំងលក្ខណៈរឹង និងទន់។ |
| ៤ | ការស្លៀកពាក់មិនសមរម្យ | PROV | គេហទំព័រដែលបង្ហាញការស្លៀកពាក់មិនសមរម្យ និងបង្ហាញពីស្ត្រីក្នុងលក្ខណៈស្រើបស្រាលផ្លូវភេទ ដោយការស្លៀកសម្លៀកបំពាក់ខើចខ្លី។ |

| | | | |
|---|---|---|---|
| ៥ | ការរិះគន់នយោបាយ | POLR | មាតិកាដែលផ្តល់នូវទស្សនៈនយោបាយសំខាន់ៗ។ រួមបញ្ចូលអ្នកនិពន្ធបែបរិះគន់ និងអ្នកសរសេរប្លុក ក៏ដូចជាអង្គការនយោបាយប្រឆាំង។ រួមបញ្ចូលខ្លឹមសារគាំទ្រលទ្ធិប្រជាធិបតេយ្យ ខ្លឹមសារប្រឆាំងអំពើពុករលួយ ក៏ដូចជាខ្លឹមសារដែលអំពាវនាវឱ្យមានការផ្លាស់ប្តូរការដឹកនាំ បញ្ហាអភិបាលកិច្ច កំណែទម្រង់ច្បាប់។ ល។ |
| ៦ | បញ្ហាសិទ្ធិមនុស្ស | HUMR | គេហទំព័រដែលមប្រើដល់ការពិភាក្សាអំពីបញ្ហាសិទ្ធិមនុស្សក្នុងទម្រង់ផ្សេងៗ។ រួមបញ្ចូលសិទ្ធិស្ត្រី និងសិទ្ធិរបស់ជនជាតិភាគតិច។ |
| ៧ | បរិស្ថាន | ENV | ការបំពុល សន្ធិសញ្ញាបរិស្ថានអន្តរជាតិ ការកាប់បំផ្លាញព្រៃឈើ យុត្តិធម៌បរិស្ថាន គ្រោះមហន្តរាយ។ ល។ |
| ៨ | អំពើភេរវកកម្ម និងក្រុមសកម្មប្រយុទ្ធ | MILX | គេហទំព័រផ្សព្វផ្សាយអំពើភេរវកម្ម ចលនាសកម្មប្រយុទ្ធបែបហិង្សា ឬចលនាផ្តាច់ខ្លួន។ |
| ៩ | ពាក្យសម្តីស្អប់ខ្ពើម | HATE | មាតិកាដែលប្រមាថមើលងាយក្រុម ឬមនុស្សជាក់លាក់ដោយផ្អែកលើជាតិសាសន៍ ភេទ ភេទ ឬលក្ខណៈផ្សេងទៀត។ |
| ១០ | សារព័ត៌មាន | NEWS | ប្រភេទនេះរួមមានបណ្តាញព័ត៌មានសំខាន់ៗ (BBC, CNN ។ល។) ក៏ដូចជាបណ្តាញព័ត៌មានក្នុងតំបន់ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ |
| ១១ | ការអប់រំផ្លូវភេទ | XED | រួមបញ្ចូលការពន្យារកំណើត តំណម ជំងឺកាមរោគ សុខភាពផ្លូវភេទ ការមានផ្ទៃពោះក្នុងវ័យជំទង់ ការការពារការចាប់រំលោភ ការរំលូតកូន សិទ្ធិផ្លូវភេទ និងសេវាសុខភាពផ្លូវភេទ។ |
| ១២ | សុខភាពសាធារណៈ | PUBH | មេរោគអេដស៍ ជំងឺសារ ជំងឺផ្តាសាយបក្សី មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ អង្គការសុខភាពពិភពលោក។ល។ |
| ១៣ | ល្បែងស៊ីសង | GMB | គេហទំព័រលេងល្បែងអនឡាញ។ រួមបញ្ចូលហ្គេមកាស៊ីណូ ការភ្នាល់កីឡា។ល។ |

| | | | |
|---|---|---|---|
| ១៤ | ឧបករណ៍អនាមិក និង ឧបករណ៍បញ្ចៀស | ANON | គេហទំព័រដែលផ្តល់ឧបករណ៍ដែលប្រើសម្រាប់អនាមិក ការបញ្ចៀស សេវាប្រូកស៊ី និងកូដនីយកម្ម។ |
| ១៥ | ការណាត់ជួបតាមអនឡាញ | DATE | សេវាកម្មណាត់ជួបតាមអនឡាញដែលអាចប្រើដើម្បីជួបគ្នា បង្ហោះកម្រងព័ត៌មាន ជជែកកំសាន្តជាដើម។ |
| ១៦ | ទំនាក់ទំនងបណ្តាញសង្គម | GRP | ឧបករណ៍ និងវេទិកាទំនាក់ទំនងបណ្តាញសង្គម។ |
| ១៧ | អ្នកស្រលាញ់ភេទដូចគ្នា | LGBT | ប្រភេទទាក់ទងនឹងបញ្ហាបុរសស្រឡាញ់ភេទដូចគ្នា-ស្ត្រីស្រឡាញ់ភេទដូចគ្នា-ខ្ទើយ-អ្នកកែភេទ។ (មិនរាប់បញ្ចូលភាពអាសអាភាស) |
| ១៨ | ការចែករំលែកឯកសារ | FILE | គេហទំព័រ និងឧបករណ៍ដែលប្រើដើម្បីចែករំលែកឯកសារ រួមទាំងការផ្ទុកឯកសារខ្លោត (cloud) តូរ៉េង់ (torrents) និងឧបករណ៍ចែករំលែកឯកសារ P2P |
| ១៩ | ឧបករណ៍លួចចូល | HACK | គេហទំព័រដែលបម្រើដល់សុវត្ថិភាពកុំព្យូទ័រ រួមទាំងព័ត៌មាន និងឧបករណ៍។ រួមបញ្ចូលមាតិកាបែបព្យាបាទ និងមិនព្យាបាទ។ |
| ២០ | ឧបករណ៍ទំនាក់ទំនង | COMT | គេហទំព័រ និងឧបករណ៍សម្រាប់ទំនាក់ទំនងបុគ្គល និងក្រុម។ រួមបញ្ចូលទាំង webmail, VoIP,កម្មវិធីផ្ញើសារភ្លាមៗ ជជែកកំសាន្ត និងផ្ញើសារតាមទូរស័ព្ទ។ |
| ២១ | ការចែករំលែកប្រព័ន្ធផ្សព្វផ្សាយ | MMED | វេទិកាចែករំលែកវីដេអូ សំឡេងអូឌីយ៉ូ ឬរូបថត។ |
| ២២ | វេទិកាបង្ហោះ និងប្លុក | HOST | សេវាកម្មបង្ហោះគេហទំព័រ ប្លុក និងវេទិកាផ្សព្វផ្សាយតាមអនឡាញផ្សេងទៀត។ |
| ២៣ | ម៉ាស៊ីនស្វែងរក | SRCH | ម៉ាស៊ីនស្វែងរក និងផតថល។ |
| ២៤ | ហ្គេមកំសាន្ត | GAME | ហ្គេមអនឡាញ និងវេទិកាហ្គេម ដោយមិនរាប់បញ្ចូលគេហទំព័រល្បែងស៊ីសង។ |
| ២៥ | វប្បធម៌ | CULTR | ខ្លឹមសារទាក់ទងនឹងការកម្សាន្ត ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ តន្ត្រី ភាពយន្ត សៀវភៅ ការនិពន្ធបែបចំអក និងកំប្លែង។ |

| | | | |
|---|---|---|---|
| ២៦ | សេដ្ឋកិច្ច | ECON | ការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ និងភាពក្រីក្រទាក់ទងនឹងប្រធានបទ ភ្នាក់ងារ និងឱកាសផ្តល់មូលនិធិ។ |
| ២៧ | រដ្ឋាភិបាល | GOVT | គេហទំព័រគ្រប់គ្រងដោយរដ្ឋាភិបាល រួមទាំងគេហទំព័រយោធា។ |
| ២៨ | ពាណិជ្ជកម្មអេឡិចត្រូនិច | COMM | គេហទំព័រនៃសេវាកម្មពាណិជ្ជកម្ម និងផលិតផល។ |
| ២៩ | ការគ្រប់គ្រងមាតិកា | CTRL | មាតិកាមិនបង្កគ្រោះថ្នាក់ ឬមិនបង្កអន្តរាយ ប្រើជា ការគ្រប់គ្រង។ |
| ៣០ | អង្គការអន្តររដ្ឋាភិបាល | IGO | គេហទំព័ររបស់អង្គការអន្តររដ្ឋាភិបាល ដូចជាអង្គការសហប្រជាជាតិ។ |
| ៣១ | មាតិកាផ្សេងៗ | MISC | គេហទំព័រដែលមិនសមនឹងប្រភេទណាមួយ (XXX អ្វីដែលនៅទីនេះគួរតែត្រូវបានចាត់ថ្នាក់) |

## អាសយដ្ឋាន IP និងព័ត៌មានផ្សេងទៀត

គម្រោង OONI មិនប្រមូលយក ឬរក្សាទុកអាសយដ្ឋាន IP របស់អ្នកប្រើប្រាស់ដោយចេតនានោះទេ។ ដើម្បីការពារអ្នកប្រើប្រាស់របស់ខ្លួនពីហានិភ័យដែលអាចកើតមាន គម្រោង OONI ចាត់វិធានការដើម្បីដកយកវាចេញពីការវាស់វែងដែលបានប្រមូលបាន។ ទោះយ៉ាងណាក៏ដោយ ប្រហែលជាអាចមានករណីដែលអាសយដ្ឋាន IP របស់អ្នកប្រើប្រាស់ និងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនសក្តានុពលផ្សេងទៀតត្រូវបានប្រមូលយកដោយអចេតនា ប្រសិនបើព័ត៌មានទាំងនោះត្រូវបានរួមបញ្ចូលនៅតួខាងលើ HTTP ឬទិន្នន័យមេតានៃការវាស់វែងផ្សេងទៀត។ ជាឧទាហរណ៍ វាអាចកើតឡើងបានប្រសិនបើគេហទំព័រដែលបានធ្វើតេស្តរួមមានបច្ចេកវិទ្យាតាមដាន ឬមាតិកាផ្ទាល់ខ្លួនផ្អែកលើទីតាំងបណ្តាញរបស់អ្នកប្រើប្រាស់ផ្ទាល់។

## ការវាស់វែងបណ្តាញ

ប្រភេទនៃការវាស់វែងបណ្តាញដែល OONI ប្រមូលបានគឺអាស្រ័យលើប្រភេទនៃការធ្វើតេស្តដែលបានដំណើរការ។ ភាពជាក់លាក់អំពីការធ្វើតេស្ត OONI នីមួយៗ អាចត្រូវបានមើលឃើញតាមរយៈ gitrepository របស់វា ហើយព័ត៌មានលម្អិតអំពីអ្វីដែលការវាស់វែងបណ្តាញប្រមូលបាន អាចមើលឃើញតាមរយៈ OONI Explorer ឬតាមរយៈ OONI’smeasurementAPI ។

ដើម្បីទទួលបានអត្ថន័យពីការវាស់វែងដែលប្រមូលបាន OONI ដំណើរការប្រភេទទិន្នន័យដែលបានរៀបរាប់ខាងលើដើម្បីឆ្លើយតបសំណួរខាងក្រោម៖

- តើការធ្វើតេស្ត OONI ប្រភេទណាខ្លះត្រូវបានដំណើរការ?
- តើការធ្វើតេស្តទាំងនោះដំណើរការនៅប្រទេសណាខ្លះ?
- តើការធ្វើតេស្តទាំងនោះដំណើរការលើបណ្តាញណាខ្លះ?
- តើការសាកល្បងបានដំណើរការនៅពេលណា?
- តើមានការជ្រៀតជ្រែកបណ្តាញប្រភេទណាខ្លះ?
- តើការជ្រៀតជ្រែកបណ្តាញកើតឡើងនៅប្រទេសណា?
- តើបណ្តាញណាដែលរំខានបណ្តាញកើតឡើង?
- តើការជ្រៀតជ្រែកបណ្តាញកើតឡើងនៅពេលណា?
- តើការជ្រៀតជ្រែកបណ្តាញកើតឡើងយ៉ាងដូចម្តេច?

ដើម្បីឆ្លើយសំណួរបែបនេះ លំហូរទិន្នន័យរបស់ OONI ត្រូវបានរចនាឡើងដើម្បីឆ្លើយសំណួរទាំងងនេះ ដោយដំណើរការទិន្នន័យវាស់វែងបណ្តាញ ដើម្បីបើកដំណើរការ ដូចខាងក្រោម៖

- កំណត់ការវាស់វែងទៅប្រទេសជាក់លាក់មួយ។
- កំណត់ការវាស់វែងទៅបណ្តាញជាក់លាក់មួយក្នុងប្រទេសមួយ។
- បែងចែកការវាស់វែងដោយផ្អែកលើការធ្វើតេស្តជាក់លាក់ដែលត្រូវបានដំណើរការសម្រាប់ការប្រមូលយក។
- បែងចែករវាងការវាស់វែង "ធម្មតា" និង "មិនធម្មតា" (ជាចុងក្រោយ បង្ហាញថាទម្រង់នៃការរំខានបណ្តាញទំនងជាមានវត្តមាន)។
- កំណត់អត្តសញ្ញាណប្រភេទនៃការជ្រៀតជ្រែកបណ្តាញដោយផ្អែកលើលទ្ធផលនៃការសិក្សាលំអិតសម្រាប់ការរារាំងនៃប្រព័ន្ធ DNS ការបិទខ្ទប់ TCP/IP និងការបិទខ្ទប់ HTTP ។

- កំណត់អត្តសញ្ញាណទំព័របិទខ្ទប់ផ្អែកលើលទ្ធផលការវិភាគលំអិតសម្រាប់ការបិទខ្ទប់ HTTP ។
- កំណត់អត្តសញ្ញាណវត្តមាននៃ "Middle box" នៅក្នុងបណ្តាញដែលបានសាកល្បង។

យោងតាម OONI ភាពវិជ្ជមានមិនពិត អាចកើតឡើងនៅក្នុងទិន្នន័យដែលបានដំណើរការដោយសារហេតុផលមួយចំនួន។ ឧបករណ៍ដោះស្រាយប្រព័ន្ធ DNS (ដំណើរការដោយ Google ឬ ISP ក្នុងស្រុក) ជារឿយៗផ្តល់ឱ្យអ្នកប្រើប្រាស់នូវអាសយដ្ឋាន IP ដែលស្ថិតនៅជិតពួកគេតាមភូមិសាស្ត្រនីមួយៗ។ ប្រសិនបើមើលទៅដូចជាករណីនៃការរារាំងនៃប្រព័ន្ធ DNS គឺពិតជាត្រូវបានធ្វើឡើងដោយមានបំណងផ្តល់ឱ្យអ្នកប្រើប្រាស់នូវការចូលប្រើគេហទំព័របានកាន់តែលឿនជាងមុន។ ដូចគ្នានេះដែរ ភាពវិជ្ជមានមិនពិតអាចលេចឡើងនៅពេលដែលគេហទំព័រដែលបានធ្វើតេស្តបម្រើមាតិកាផ្សេងៗគ្នា អាស្រ័យលើប្រទេសអ្នកប្រើប្រាស់កំពុងតភ្ជាប់ ឬនៅពេលដែលគេហទំព័រត្រឡប់មកជាបរាជ័យ ទោះបីជាវាមិនត្រូវបានរំខានក៏ដោយ។

លើសពីនេះ ការវាស់វែងដែលបង្ហាញពីការបិទខ្ទប់ HTTP ឬ TCP/IP ពិតជាអាចបណ្តាលមកពី HTTP ឬ TCP/IP បរាជ័យជាបណ្តោះអាសន្ន ប្រហែលមិនមែនជាសញ្ញានៃការជ្រៀតជ្រែកបណ្តាញនោះទេ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើតេស្តសំណុំគេហទំព័រដូចគ្នានៅទូទាំងពេលវេលា និងទិន្នន័យដែលទាក់ទងគ្នា មុនពេលឈានដល់ការសន្និដ្ឋានថាតើគេហទំព័រនោះពិតជាត្រូវបានបិទខ្ទប់មែន ឬយ៉ាងណា។

ដោយសារទំព័រប្លុកមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងជួនកាលសូម្បីតែពីបណ្តាញមួយទៅបណ្តាញ វាពិតជាលំបាកណាស់ក្នុងការកំណត់អត្តសញ្ញាណទំព័រប្លុកឱ្យបានត្រឹមត្រូវ។ OONI ប្រើស៊េរីនៃទិន្នន័យលំអិត ដើម្បីព្យាយាមទស្សន៍ទាយថាតើទំព័រនៅក្នុងសំណួរខុសគ្នាពីការគ្រប់គ្រងដែលរំពឹងទុកឬអត់ ប៉ុន្តែទិន្នន័យលំអិត ទាំងនេះជារឿយៗអាចផ្តល់លទ្ធផលវិជ្ជមានមិនពិត។ សម្រាប់ហេតុផលនេះ OONI បញ្ជាក់តែឧទាហរណ៍នៃការបិទខ្ទប់នៅពេលដែលទំព័រប្លុកត្រូវបានរកឃើញ។

តាមរយៈការប្រមូលផ្តុំការវាស់វែងបណ្តាញកាន់តែច្រើនឡើងៗ OONI បន្តបង្កើតការវិភាគទិន្នន័យរបស់ខ្លួនដោយផ្អែកលើអ្វីដែលជាការព្យាយាមកំណត់អត្តសញ្ញាណព្រឹត្តិការណ៍ត្រួតពិនិត្យពិរុទ្ធភាពឱ្យបានត្រឹមត្រូវ។

បញ្ជីពេញលេញនៃប្រទេសជាក់លាក់ដែលមានគេហទំព័រត្រូវបានបញ្ជាក់ថាបិទខ្ទប់នៅក្នុងប្រទេសមីយ៉ាន់ម៉ា កម្ពុជា ហុងកុង ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម អាចមើលឃើញនៅទីនេះ៖ https://github.com/citizenlab/test-lists។

## ការផ្ទៀងផ្ទាត់ការវាស់វែង OONI

ការវាស់វែង OONI ដែលបានបញ្ជាក់ថាបិទខ្ទប់ គឺធ្វើឡើងផ្អែកលើស្នាមម្រាមដៃដែលបានកត់ត្រានៅទីនេះ https://github.com/ooni/blocking-fingerprints។ ស្នាមម្រាមដៃទាំងនេះ គឺផ្អែកលើការរារាំងនៃប្រព័ន្ធ DNS ឬ HTTP។ ស្នាមម្រាមដៃដែលបានកត់ត្រាថាជាការបិទខ្ទប់ដែលបានបញ្ជាក់ គឺត្រូវបានអនុវត្តជាលក្ខណៈប្រទេស ឬដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតផ្ទាល់។

ហេតុដូច្នេះហើយ ការស្ទង់មតិខាងក្រោមត្រូវបានដំណើរការលើការវាស់វែងឆៅសម្រាប់ប្រទេសទាំងអស់ដែលស្ថិតនៅក្រោមគម្រោង iMAP ដើម្បីបញ្ជាក់បន្ថែមអំពីការបិទខ្ទប់។

ជាដំបូង អាសយដ្ឋាន IP ដែលមានដែនច្រើនជាង ១០ ត្រូវបានកំណត់អត្តសញ្ញាណ។ បន្ទាប់មកអាសយដ្ឋាន IP នីមួយៗត្រូវបានពិនិត្យ ដូចខាងក្រោម៖

| តើ IP នៅក្នុងចំណុចសួរ ទៅកាន់ទំព័រប្លុករបស់រដ្ឋាភិបាលដែរឬទេ? | | | | |
|---|---|---|---|---|
| រួចរាល់ | ទេ គេហទំព័រផុតពេល ឬបង្ហាញទំព័របណ្តាញចែកចាយមាតិកា (CDN)។ | | | |
| ↓ | ↓ | | | |
| **ការបិទខ្ទប់ ដែលបានបញ្ជាក់** | តើព័ត៌មានអ្វីខ្លះដែលយើងអាចទទួលបានអំពី IP ដោយធ្វើការស្វែងរកអ្នកណា? | | | |
| | រដ្ឋាភិបាល ឬ ISP ក្នុងស្រុក* | CDN / IP ឯកជន | | |
| | ↓ | ↓ | | |
| | **ការបិទខ្ទប់ ដែលបានបញ្ជាក់** | តើយើងទទួលបានវិញ្ញាបនបត្រ TLS ត្រឹមត្រូវសម្រាប់ដែនណាមួយដែលមានសំណួរនៅពេលធ្វើការចាប់ដៃ TLS និងបញ្ជាក់ SNI ដែរឬទេ? | | |
| | | រួចរាល់ | ទេ មានការទប់ស្កាត់ស្នាមម្រាមដៃត្រូវបានរកឃើញ។ | ទេ ផុតពេលហើយ។ |
| | | ↓ | ↓ | ↓ |
| | | **វិជ្ជមានមិនពិត** | **ការបិទខ្ទប់ដែលបានបញ្ជាក់** | ការវាស់វែងគំរូត្រូវបានវិភាគនៅលើ OONI Explorer ។ |

*ចំណាំ៖ ក្នុងករណីនៅប្រទេសឥណ្ឌា មានភស្តុតាងនៃគេហទំព័រពេញនិយមដែលបានបង្ហោះទំព័ររបស់ពួកគេនៅលើបណ្តាញ ISPs សម្រាប់ពេលវេលាផ្ទុកលឿនជាងមុន ដោយសារពេលខ្លះ ISPs ផ្តល់សេវាកម្មបណ្តាញតែមបែបនេះ ដូច្នេះគេហទំព័រដែលប្តូរទិសទៅគេហទំព័រក្នុងស្រុកត្រូវបានសម្គាល់សម្រាប់តែជាប្រភេទ "ត្រូវបានបិទខ្ទប់ដោយសក្តានុពល"។

នៅពេលដែលការបិទខ្ទប់ត្រូវបានកំណត់ ដែនណាមួយដែលបានបញ្ជូនបន្តទៅកាន់អាសយដ្ឋាន IP ទាំងនេះនឹងត្រូវបានសម្គាល់ថាជា "dns.confirmed"។

ជាបន្ទាប់ ចំណងជើង និងតួ HTTP ត្រូវបានវិភាគដើម្បីកំណត់ទំព័រប្លុក។ ឧទាហរណ៍នេះ example បង្ហាញថា HTTP ត្រឡប់អត្ថបទ "URL ត្រូវបានបិទខ្ទប់តាមការណែនាំរបស់ DoT ដោយអនុលោមតាមដីការបស់តុលាការ"។ ដែនណាមួយដែលបានបញ្ជូនបន្តទៅកាន់ចំណងជើង និងតួខាងលើ HTTP ទាំងនេះ នឹងត្រូវបានសម្គាល់ថា "http.confirmed" ។

ជាលទ្ធផល ភាពវិជ្ជមានមិនពិតត្រូវបានលុបចោល ហើយទទួលបាននូវការបញ្ជាក់ថាបានបិទខ្ទប់បន្ថែមទៀត។

នៅក្នុងរបាយការណ៍ឆ្នាំ២០២២ មានតែការបិទខ្ទប់ដែលបានបញ្ជាក់ដោយផ្អែកលើ OONI ឬស្នាមម្រាមដៃថ្មីប៉ុណ្ណោះ ដែលត្រូវបានគេរាយការណ៍។

សម្រាប់ការរាយការណ៍ក្នុងជុំនេះក្នុងឆ្នាំ២០២៣ យើងបានកំណត់អត្តសញ្ញាណនៃការបិទខ្ទប់បន្ថែមទៀតដោយផ្ទៀងផ្ទាត់ការបិទខ្ទប់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ព័ត៌មាន រួមជាមួយនឹងការវាស់វែង OONI។ ចំណុចនេះគឺដោយសារតែមានការបិទខ្ទប់ដែលមិនអាចកំណត់អត្តសញ្ញាណបានតាមរយៈការប្រើស្នាមម្រាមដៃនៃប្រព័ន្ធ DNS ឬ HTTP ។ ជាធម្មតា គេហទំព័រទាំងនេះត្រូវបានបញ្ជូនបន្តទៅកាន់អាសយដ្ឋាន IP ដែលមិនស្គាល់អត្តសញ្ញាណ ឬ (bogon) ឬគេហទំព័រទាំងនោះមានកំហុសឆ្លងនាំឱ្យមិនស្គាល់ផ្សេងទៀត ហើយដែលមានភាពមិនច្បាស់លាស់ត្រង់ថាតើវាជាវិជ្ជមានពិត ឬមិនពិតនៃការត្រួតពិនិត្យពិរុទ្ធភាព។ ហេតុដូច្នេះហើយ ដោយផ្អែកលើរបាយការណ៍ព័ត៌មានដែលគេហទំព័រទាំងឡាយត្រូវបានបិទខ្ទប់ ត្រូវបានដកស្រង់យកមកបង្ហាញ ហើយការបិទខ្ទប់ត្រូវបានរកឃើញបន្ថែមទៀតដោយការប្រៀបធៀបការវាស់វែងដែលមាននៅលើកម្មវិធី OONI។ សម្រាប់ការសិក្សានេះ យើងបានកត់សម្គាល់គេហទំព័រទាំងនោះថាជាការបិទខ្ទប់ដែលបានបញ្ជាក់ ប្រសិនបើមានការវាស់វែងលើសពី ៣០ និងអត្រាភាពមិនប្រក្រតីលើសពី ១% ក្នុងរយៈពេលមួយឆ្នាំនៃការសិក្សានេះ។ លើសពីនេះទៀត យើងបានពិនិត្យការវាស់វែងកម្មវិធី OONI ដោយដៃ តាមរយៈការត្រួតពិនិត្យឆ្លងកាត់បណ្តាញ តាមប្រទេសនីមួយៗ និងតាមរយៈពេលកំណត់។